ក្រសួង អប់រំ ជាតិ

# ប្រវត្តិវិទ្យា

ថ្នាក់ ទី ៣

ខេមរយានកម្ម

តែ ម៉េងហាប់
ម៉ៃ លន់

ឃិន សុខ
ម៉ក់ ភីន
ប៉ែន ណារុណ

# ប្រវត្តិវិទ្យា

## ថ្នាក់ទី ៣

គណៈកម្មាធិការជាតិអចិន្ត្រៃយខេមរយានកម្ម
ភ្នំពេញ ១៩៧៣
រក្សាសិទ្ធិ

# កថាមុខ

សៀវភៅដែលលោកអ្នកនាងកាន់នៅដៃនេះ ជាសមិទ្ធិដែលប្រសូតចេញពីការខិតខំរបស់គណៈកម្មាធិការជាតិអចិន្ត្រៃយ៍នៃខេមរយានកម្ម ដើម្បីផ្សព្វផ្សាយចំណេះវិជ្ជា និងពង្រីកវប្បធម៌ឲ្យមានជំហរមាំទាំ បង្កើតបានជាមនសិការជាតិមួយរស់ជានិរន្តរ៍ ក្នុងសន្តានចិត្តកូនខ្មែរ គ្រប់កាលៈទេសៈ ។

តាមគំរោងការរបស់ក្រសួងអប់រំជាតិ អនុវត្តន៍ខេមរយានកម្មសិក្សានៅមធ្យមសិក្សាត្រូវចប់សព្វគ្រប់ក្នុងរយៈពេលប្រាំពីរឆ្នាំ គឺចាប់ពីថ្នាក់ទី ៦ ដល់ថ្នាក់ទីបញ្ចប់ ។

ទោះបីគណៈកម្មាធិការជាតិខ្វះខាតទាំងសព្វទាំងគ្រប់យ៉ាងណាក៏ដោយ ដូចជាបុគ្គលិកមានសមត្ថភាពពេញលេញក្នុងមុខវិជ្ជានីមួយៗ មានចំនួនមិនគ្រប់គ្រាន់ ឯកសារសិក្សានិងសំភារៈប្រើប្រាស់ខ្វះខាតមុខក្រោយ ឥណទានផ្គត់ផ្គង់កិច្ចការផ្សេងៗដើម្បីឲ្យដើរបានទៀងទាត់និងទាន់ពេលវេលា ស្ទើរតែគ្មានសោះ កំលាំងចិត្តថានឹងសំរេចឲ្យបានជោគជ័យនៅតែពុះកញ្ជ្រោលជានិច្ច ដើម្បីជំរុញកិច្ចការខេមរយានកម្មឲ្យដើរបានយ៉ាងគួរសម ។

វិធានការជាច្រើន ដើម្បីស្កាត់កុំឲ្យឧបសគ្គដដែលៗកើតឡើងជាថ្មីទៀត ក្នុងពេលដែលនឹងមកដល់ សុទ្ធតែបានត្រូវចាត់ជាមុនស្រេច ។ ហើយដែលនៅមានការរអាក់រអួលខ្លះនោះ ក៏អាចបានជាមេរៀនសំរាប់ពិចារណារកវិធានការថ្មីទៀត ដើម្បីសំរួលការប្រព្រឹត្តទៅនៃដំណើរខេមរយានកម្មនៅថ្នាក់លើៗ ឲ្យមានប្រសិទ្ធិភាពគួរជាទំនុកចិត្ត ។

ដើម្បីសំរេចបំណងនេះបាន គណៈកម្មាធិការជាតិរង់ចាំជានិច្ចនឹងទទួលសំណើនិងយោបល់ពីលោកអ្នកសិក្សាអប់រំ ទោះជាក្នុងន័យបែបណាក៏ដោយ ដើម្បីបានជាគោលគំនិតសំអិតសំអាងកិច្ចការខេមរយានកម្ម ទាំងផ្នែកបច្ចេកទេស ទាំងផ្នែកចិត្ត-គរុកោសល្យ ឲ្យបានជាប្រភពមួយផ្តល់មកនូវប្រសិទ្ធិភាពចំពោះគ្រប់បំណងនៃអប់រំ និងវប្បធម៌ជាតិយើង ។

គណៈកម្មាធិការជាតិ

# អារម្ភកថា

សៀវភៅប្រវត្តិវិទ្យាថ្នាក់ទី ៣ នេះត្រូវបានរៀបចំឡើងស្របទៅតាមកម្មវិធីសិក្សា ដើម្បីតំរូវទៅតាមសេចក្តីត្រូវការនៃសាស្ត្រាចារ្យ និងសិស្សានុសិស្ស ក្នុងកិច្ចអនុវត្តខេមរយានកម្មក្នុងការសិក្សា ។

ក្នុងការរៀបចំមេរៀន គណៈកម្មការបច្ចេកទេសបានច្បូចយកនូវចំណុចសំខាន់ៗដែលគប្បីមិនត្រូវភ្លេច ហើយទុកលទ្ធភាពឲ្យសាស្ត្រាចារ្យធ្វើការស្រាវជ្រាវផ្ទាល់ខ្លួនថែមទៀត ដើម្បីញាំងការបង្ហាត់បង្រៀនសិស្សឲ្យមានប្រសិទ្ធិភាពឡើង ។ ដូចនេះ សៀវភៅប្រវត្តិវិទ្យាថ្នាក់ទី ៣ នេះពុំអាចជំនួសគ្រូទាំងស្រុងបានឡើយ តែត្រូវចាត់ទុកជាជំនួយមួយតែប៉ុណ្ណោះ ។

គណៈកម្មការបច្ចេកទេស បានខំរៀបចំឲ្យមានទំនាក់ទំនងពីព្រឹត្តិការណ៍មួយ ទៅព្រឹត្តិការណ៍មួយ ដើម្បីបង្ហាញនូវបុព្វហេតុ និងវិបាក ហើយប្រសិនបើសិស្សអាចចាប់បាននូវគោលគំនិតទាំងនេះ គឺទុកជាបានសំរេចមួយភាគធំនៃគោលដៅរបស់សៀវភៅនេះដែរ ។

មេរៀននីមួយៗបញ្ចប់ដោយសំណួរ ដើម្បីត្រួតពិនិត្យឡើងវិញនូវការយល់និងចងចាំរបស់សិស្ស ។ សាស្ត្រាចារ្យអាចបន្ថែមបន្ថយសំណួរទាំងនោះទៅតាមអធ្យាស្រ័យរបស់ខ្លួន ។

ការរៀបចំជាលើកដំបូង នូវសៀវភៅប្រវត្តិវិទ្យាថ្នាក់ទី ៣ នេះ មុខជានឹងមានកង្វះខាតមិនខានឡើយ ទាំងខាងបច្ចេកទេស ទាំងខាងចិត្ត-គរុកោសល្យ ព្រមទាំងខាងវិធីសាស្ត្រ ។ គណៈកម្មការសង្ឃឹមលើសហប្រតិបត្តិការរបស់គ្រប់សាស្ត្រាចារ្យ ក្នុងការផ្តល់មតិនិងយោបល់ដើម្បីនឹងធ្វើឲ្យសៀវភៅប្រវត្តិវិទ្យាថ្នាក់ទី ៣ នេះឲ្យបានរឹតតែប្រសើរថែមទៀត ។

គណៈកម្មការបច្ចេកទេសប្រវត្តិវិទ្យាជឿជាក់ថា ទោះជាមានកង្វះខាត

ដូចបានរៀបរាប់ខាងលើគឺដោយ  ក៏សៀវភៅប្រវត្តិវិទ្យាថ្នាក់ទី ៣ នេះអាចចាត់ទុកជាឧបករណ៍  និងជាជំនួយមួយដ៏សំខាន់ចំពោះសាស្ត្រាចារ្យក្នុងការបង្ហាត់បង្រៀន  ហើយជាមិត្តមួយដ៏ប្រសើររបស់សិស្សក្នុងការសិក្សាមុខវិជ្ជានេះ ។ ជាពិសេស  សៀវភៅប្រវត្តិវិទ្យាថ្នាក់ទី ៣ នេះជាវិភាគទានមួយដើម្បីជោគជ័យនៃអនុវត្តន៍ខេមរយានកម្មក្នុងការសិក្សាទៀតផង ។

## បញ្ជាក់ចំពោះបំណោះពុម្ពលើកទី ២

ក្នុងបំណោះពុម្ពលើកទី ២ នេះ  គ.ក.ប.ប្រវត្តិវិទ្យាបានសំរេចប្តូរលំដាប់មេរៀន ឲ្យស្របទៅនឹងលំដាប់លំដោយព្រឹត្តិការណ៍នានា ។ ម្យ៉ាងទៀត គ.ក.ប.បានកែតំរូវអក្ខរាវិរុទ្ធនៃពាក្យខ្លះទៅតាមគោលពាក្យ  ដែលគណៈកម្មការចំរុះសំរេចឲ្យអនុវត្ត ។

គ.ក.ប. ប្រវត្តិវិទ្យា

# បញ្ជីអត្ថបទ


## ១. ពិភពលោកពីឆ្នាំ ១៨៧០ ដល់ ១៩១៩

ក. រូបភាពថ្មីនៃអរិយធម៌នាសតវត្សទី ១៩ និងទី ២០

១. ការរីកចំរើននៃអរិយធម៌ វិទ្យាសាស្ត្រ និងឧស្សាហកម្ម នៅសតវត្សទី ១៩ និងទី ២០ 1

២. ចលនាគំនិត អក្សរសាស្ត្រ និងសិល្បៈនៅសតវត្ស ទី ១៩ និងទី ២០ 18

ខ. មហាអំណាចក្នុងលោកមុនសង្គ្រាមលោកលើកទី ១

៣. ចក្រភពអាល្លឺម៉ង់ពីឆ្នាំ ១៨៧១ ដល់ ១៩១៤ 26

៤. ប្រទេសអង់គ្លេសពីឆ្នាំ ១៨៦៥ ដល់ ១៩១៤ 33

៥. ប្រទេសបារាំងពីឆ្នាំ ១៨៧១ ដល់ ១៩១៤ 42

៦. សហរដ្ឋអាមេរិចពីឆ្នាំ ១៨៦០ ដល់ ១៩១៤ 52

៧. ចក្រភពរូស៊ីពីឆ្នាំ ១៨៥៥ ដល់ ១៩១៧ 61

៨. ប្រទេសចិននិងប្រទេសជប៉ុនពីឆ្នាំ ១៨៤០ ដល់ ១៩១៤ 74

គ. ការប្រកួតប្រណាំងអន្តរជាតិពី ឆ្នាំ ១៩០៤ ដល់ ១៩១៤

៩. ការប្រកួតប្រណាំងខាងសេដ្ឋកិច្ចនិងខាងអាណានិគម 87

១០. សង្គ្រាមលោកលើកទី ១ ពីឆ្នាំ ១៩១៤ ដល់ ១៩១៨ 93

១១. សន្ធិសញ្ញាសន្តិភាពនិងសង្គមប្រជាជាតិ 100

១២. ការបាត់តុល្យភាពនៅក្រោយសង្គ្រាមលោកលើកទី ១ 105

## ២. ពិភពលោកពីឆ្នាំ ១៩១៩ ដល់ ១៩៤៥

ក. មហាអំណាចនានា ក្រោយសង្គ្រាមលោកលើកទី ១

*១៣. សហភាពសូវៀតពីឆ្នាំ ១៩១៧ ដល់ ១៩៣៩* 112

*១៤. ប្រទេសបារាំងនិងអង់គ្លេសពីឆ្នាំ ១៩១៩ ដល់ ១៩៣៩* 119

*១៥. សហរដ្ឋអាមេរិចពីឆ្នាំ ១៩១៩ ដល់ ១៩៣៩* 128

*១៦. ប្រទេសអ៊ីតាលីនិងអាឡឺម៉ង់ពីឆ្នាំ ១៩១៩ ដល់ ១៩៣៩* 133

*១៧. ប្រទេសចិននិងជប៉ុនពីឆ្នាំ ១៩១៩ ដល់ ១៩៣៩* 146

ខ. ដំណើរឆ្ពោះទៅរកសង្គ្រាម

*១៨. បញ្ហាសំខាន់ៗនៅមុនសង្គ្រាមលោកលើកទី ២* 153

*១៩. សង្គ្រាមលោកលើកទី ២ ឆ្នាំ ១៩៣៩—១៩៤៥* 160

## ៣. ពិភពលោកពីឆ្នាំ ១៩៤៥ ដល់ ១៩៦០

ក. មហាអំណាចខ្លះក្រោយសង្គ្រាមលោកលើកទី ២

*២០. មហាអំណាចខាងលិចក្រោយសង្គ្រាមលោកលើកទី ២* 172

*២១. ប្លុកសង្គមនិយម* 177

*២២. ប្រទេសចិននិងជប៉ុនក្រោយសង្គ្រាមលោកលើកទី ២* 182

ខ. ស្ថានភាពទូទៅក្រោយសង្គ្រាមលោកលើកទី ២

*២៣. ការរើបំរះនៃប្រជាជនពីនឹមអាណានិគម* 188

*២៤. បញ្ហានិងអង្គការអន្តរជាតិសំខាន់ៗ* 194

## ៤. ប្រទេសខ្មែរ

*២៥. ប្រទេសខ្មែរក្រោមអាណាព្យាបាលប្រទេសបារាំង* 200

# ១. ការរីកចំរើននៃអរិយធម៌ វិទ្យាសាស្ត្រ និង ឧស្សាហកម្ម នៅសតវត្សទី ១៩ និង ទី ២០

ចាប់ពីពាក់កណ្ដាលសតវត្សទី ១៩ រហូតមកទល់សព្វថ្ងៃ គឺក្នុងរយៈពេលតែមួយសតវត្សប៉ុណ្ណោះ នៅក្នុងលោកយើងនេះ មានបំរែបំរួលបំលាស់ប្ដូរច្រើន ឥតគណនា ។

ការចំរើនខាងវិទ្យាសាស្ត្រ ពិសេសខាងរូបវិទ្យា ជាមូលដ្ឋាននៃបំរែបំរួលបំលាស់ប្ដូរទាំងនោះ ដែលគេចាត់ទុកថាជាដើមសម័យថ្មីមួយនៃប្រវត្តិមនុស្សជាតិទូទៅ ។

ក្នុងវិស័យសេដ្ឋកិច្ច បំរែបំរួលមានសភាពរឹតតែពិស្ដារទៅទៀត ។ យ៉ាងណាមិញ គេសង្កេតឃើញមានបំរែបំរួលជាថ្មីនូវមធ្យោបាយនិងរបៀបបង្កើតផល នូវការប្រមូលផ្ដុំសហគ្រាសធំៗ ការលូតលាស់ខាងការបង្កើតផលនិងបណ្ដូរទំនិញ ។ល។ បដិវត្តន៍សេដ្ឋកិច្ចបានធ្វើឱ្យមានវិវត្តន៍ខាងនយោបាយ សង្គម និងវប្បធម៌ថែមទៀត ។

## ១. លក្ខណៈទូទៅក្នុងបច្ចុប្បន្នសម័យ

អំឡុងមួយសតវត្សកន្លងមកនេះ មិនជាយូរប៉ុន្មានទេ ប្រសិនបើគេប្រៀបធៀបទៅនឹងរយៈសម័យប្រវត្តិទាំងមូល ដែលមានរយៈកាលប្រមាណជាប្រាំពាន់ឆ្នាំមកហើយ ។ ប៉ុន្តែ ក្នុងរយៈពេលដ៏ខ្លីខាងលើនេះ មានបំរែបំរួលច្រើនក្រៃលែង ។ *បំលាស់ប្ដូរដ៏ឆាប់រហ័សនេះជាលក្ខណៈសំខាន់នៃបច្ចុប្បន្នសម័យ ។*

ក្នុងចំណោមបំរែបំរួលទាំងឡាយ បំលាស់ប្ដូរ បំរែបំរួលខាងសំភារៈមានលក្ខណៈសំខាន់ជាងគេទាំងអស់ ។ យ៉ាងណាមិញ ចាប់តាំងពីបឋមសម័យប្រវត្តិ ចាប់តាំងពី*ឧស្សាហកម្មថ្ម* បានត្រូវកន្លងទៅ ហើយ*ឧស្សាហកម្មលោហៈ* បានចូលមកផ្លាស់ម្ដងវិញនោះ ឧបករណ៍ប្រើប្រាស់ពុំសូវមានបំរែបំរួលប៉ុន្មានឡើយ ។ បច្ចេកទេសសិល្បករ

បារាំងក្នុងសតវត្សទី ១៨ មិនខុសពីបច្ចេកទេសសិល្បករអេស៊ីបសម័យបុរាណប៉ុន្មានឡើយ ។ បំរែបំរួល បំលាស់ប្តូរនេះទើបតែនឹងចាប់មានឡើងពីដើមសតវត្សទី ១៩ ជាបឋម នៅចក្រភពអង់គ្លេស ហើយបានលូតលាស់ទូទៅតាំងពីឆ្នាំ ១៨៥០ ។ គេអាចនិយាយបានថា មនុស្សជាតិបានឈានចូលក្នុងសម័យមួយថ្មីទៀត គឺ *សម័យម៉ាស៊ីន* និង*សម័យវិទ្យាសាស្ត្រ* ។

មិនយូរប៉ុន្មាន បំរែបំរួលក្នុងវិស័យដទៃទៀតបានធ្វើឲ្យមានបំលាស់ប្តូរខាងនយោបាយនិងខាងសង្គមមនុស្សទៀតផង ។ គេសង្កេតឃើញកំណើនប្រជាជនក្នុងលោក ពិសេសកំណើននៃវណ្ណៈកម្មករ ។ ការចាត់ចែងខាងផ្ទៃក្នុងនៃរដ្ឋក៏មានបំរែបំរួលយ៉ាងជ្រាលជ្រៅព្រមទាំងមានសារៈសំខាន់ផងទៀត ។ សកម្មភាពមនុស្សបានលាតសន្ធឹងលើផ្ទៃលោកទាំងមូល ។ ទីវាលខ្សាច់ល្ហល្ហេវប្រែក្លាយជារដ្ឋថ្មីៗ ។ ទំនាក់ទំនងអន្តរជាតិមានច្រើនឡើងៗ ជាហេតុបង្កើនបញ្ហាថ្មីៗទៀតជាច្រើន ។ គេត្រូវស៊េរីជាថ្មីឡើងវិញនូវបញ្ហាចាស់ទាំងឡាយ ដើម្បីឲ្យស្របទៅតាមកាលៈទេសៈ ។ ចំបាំងអាចក្លាយជាមហន្តរាយដ៏ធំគួរឲ្យតក់ស្លុត ។ ចំបាំងសកលលោកលើកទី ២ ជាមហាភ័យមួយដែលបានកំហែងគំរាមអាយុជីវិតអរិយធម៌ទ្វីបអឺរ៉ុបទាំងមូល ។

តើបំលាស់ប្តូរនិងបំរែបំរួលដ៏ធំមហិមានេះបណ្តាលមកពីអ្វី ? គឺពិតជាបណ្តាលមកពីវិទ្យាសាស្ត្រនេះឯង ។ គឺវិទ្យាសាស្ត្រនេះហើយ ដែលធ្វើឲ្យមានបំរែបំរួលនិងវិវត្តន៍ខាងសេដ្ឋកិច្ចព្រមជាមួយនោះ គឺវិវឌ្ឍនាការខាងនយោបាយនិងខាងសង្គមផងដែរ ។

## ២. ការចំរើនខាងវិទ្យាសាស្ត្រ

### ក. ចលនាវិទ្យាសាស្ត្រនាបច្ចុប្បន្នសម័យ

ការលូតលាស់រីកចំរើនខាងវិទ្យាសាស្ត្រចាប់មានសន្ទុះខ្លាំង តាំងពីពាក់កណ្តាលទី១ នៃស.វ. ទី ១៩ មកម្ល៉េះ ។ ឯមូលដ្ឋាននៃការចំរើននេះគឺឋិតលើវិសិដ្ឋភាពនៃការរៀបចំការងារខាងវិទ្យាសាស្ត្រនេះឯង ។ យ៉ាងណាមិញ រដ្ឋទាំងឡាយបានយកចិត្តទុកដាក់ពង្រីកការសិក្សាវិទ្យាសាស្ត្រនៅមធ្យមសិក្សា ក្នុងវិទ្យាស្ថានបច្ចេកទេស ឬសកលវិទ្យាល័យ ដែលមានចំនួនច្រើនឡើងជានិច្ច ព្រមជាមួយគ្នានោះ គេបានបង្កើតបុគ្គលិកខាង

វិទ្យាសាស្ត្រមានអ្នកប្រាជ្ញនិងអ្នកបច្ចេកទេសជាដើម បង្កើនសាលសំរាប់ធ្វើពិសោធន៍ ធ្វើឲ្យមានវិសិដ្ឋភាពខាងឧបករណ៍វិទ្យាសាស្ត្រ និងពង្រីកការស្រាវជ្រាវរិះរកនិងផលិតកម្មវិទ្យាសាស្ត្រ ។ ម្យ៉ាងទៀត ការចំរើនខាងវិទ្យាសាស្ត្រអាចប្រព្រឹត្តទៅបានឆាប់រហ័ស ដោយអាស្រ័យសហការខាងវិទ្យាសាស្ត្ររវាងអន្តរជាតិ ដោយការបោះពុម្ពផ្សាយនូវទស្សនាវដ្ដី ឬកាសែតវិទ្យាសាស្ត្រ ឬដោយការប្រជុំជាសន្និសីទ ឬសមាជនៃអ្នកប្រាជ្ញខាងវិទ្យាសាស្ត្រ ដើម្បីពិភាក្សាប្តូរយោបល់រវាងគ្នាអំពីបញ្ហានេះ ។

ខ. អំពីវិធីសាស្ត្រ

ការពង្រីកសាលពិសោធជាហេតុមួយ អនុញ្ញាតឲ្យគេប្រើប្រាស់នូវវិធីពិសោធក្នុងការរិះរកខាងវិទ្យាសាស្ត្រ ។ មិនតែប៉ុណ្ណោះ គេបានយកវិធីពិសោធនេះទៅអនុវត្តស្ទើរតែគ្រប់វិស័យ ដូចជាក្នុងជីវវិទ្យា (biologie) ចិត្តវិទ្យា (psychologie) ជាដើម ។

អាស្រ័យលើវិសិដ្ឋភាពជាលំដាប់នៃឧបករណ៍ពិសោធ គេអាចទាញយកលទ្ធផលពីពិសោធន៍នេះបានយ៉ាងជាក់លាក់ពិតប្រាកដ ពុំមានភាន់ច្រលំឡើយ ។ ក្រោយមកទៀត គេបានយកវិធីពិសោធនេះទៅផ្សំជាមួយនឹងគណិតវិទ្យា ដើម្បីរិះរកខាងវិទ្យាសាស្ត្រ ជាហេតុនាំឲ្យការរីកចំរើនរឹតតែបានឆាប់រហ័សថែមទៀត ។ ពិសោធន៍ផ្សំនឹងគណិតវិធីដែលអ្នកប្រាជ្ញយកទៅប្រើ ដើម្បីបង្ហាញទ្រឹស្តីរបស់ខ្លួន បានធ្វើឲ្យវិទ្យាសាស្ត្រលូតលាស់រីកចំរើនពុំចេះចប់ឡើយ ។ សរុបមក គេអាចសន្និដ្ឋានបានថា ការផ្សំនូវវិធីទាំងបី គឺ *ពិសោធន៍ → ការប៉ាន់គិត → សម្មតិកម្ម* ជាមធ្យោបាយមួយដ៏សំខាន់ ដែលធ្វើឲ្យវិទ្យាសាស្ត្រមានដំណើរទៅមុខជាដរាប តាមរូបមន្ត *ពិសោធន៍ → ទ្រឹស្តី → ពិសោធន៍* ។

គ. ឧត្តមភាពនៃរូបវិទ្យា

ផលិតកម្មវិទ្យាសាស្ត្រនាបច្ចុប្បន្នសម័យមានច្រើនឥតគណនា ពុំអាចរៀបរាប់ទាំងអស់បានឡើយ ។ យើងលើកយកតែរបកគំហើញសំខាន់ៗខ្លះ ដែលមានបច្ច័យទាក់ទងយ៉ាងខ្លាំងទៅលើទ្រឹស្តី ឬទៅលើអនុវត្តន៍ ។

ក្នុងករណីនេះ គេអាចកត់សំគាល់នូវឧត្តមភាពនៃរូបវិទ្យា ទៅលើវិទ្យាសាស្ត្រដទៃទៀតជាច្រើន ។ គេបានយកគោលនិយមនិងវិធីរូបវិទ្យាទៅប្រើក្នុងវិស័យដទៃទៀតជាច្រើន

ហើយតាមវិធីនេះ គេបានបង្កើតវិទ្យាសាស្ត្រថ្មីៗទៀតដូចជា *គីមីរូបវិទ្យា គីមីជីវវិទ្យា តារារូបវិទ្យា* ។ល។

## ៣. ការប្រើប្រាស់លទ្ធផលរកឃើញ

លទ្ធផលទាំងឡាយដែលគេបានរកឃើញក្នុងសម័យមុន បានត្រូវពង្រីកនិងធ្វើឲ្យមានលក្ខណៈច្បាស់លាស់ថែមទៀត សំរាប់យកទៅអនុវត្តក្នុងគ្រប់វិស័យ ដើម្បីឈានឆ្ពោះទៅរកការចំរើន ។

លោក *ហ្វ្រេណែល* (Fresnel) បានដោះស្រាយបញ្ហាស្តីពីភាពនៃពន្លឺ ហើយបានបង្ហាញឲ្យឃើញថា ពន្លឺមានភាពជារលក ។ លោក *ភូកូល* (Foucault) បានបញ្ជាក់ទ្រឹស្តីនេះថែមទៀត ព្រមទាំងបានវាស់ដោយត្រឹមត្រូវ នូវល្បឿនពន្លឺក្នុងអាកាស និងក្នុងទឹក (១៨៤៩-១៩៥៤) ។ គេបានយករង្វាស់នេះទៅប្រើប្រាស់ក្នុងវិស័យតារាវិទ្យា និងក្នុងកែវឆ្លុះថែមទៀត ។ របកគំហើញក្នុងវិស័យអេឡិចត្រូម៉ាញេទិចនិងមេដែក ដែលជាស្នាដៃរបស់លោក *អំពែ* (Ampère) និងលោក *ផារ៉ាដេ* (Faraday) បាននាំមកនូវអនុវត្តន៍ថ្មីៗទៀត ដែលមានសារៈសំខាន់ជាច្រើនទៅលើសកម្មភាពរបស់មនុស្ស ។

លោក *ថុំសុន* (Thomson) បានបង្កើតទូរលេខបាតសមុទ្រ (១៨៦៦) ។ ចំណែកលោក *ក្រាម* (Gramme) ជាតិបែលស៊ិច បានបង្កើតម៉ាស៊ីនប្រើអគ្គិសនីឌីណាម៉ូជាថាមពល (១៨៦៩) ។ លោក *គ្រាហាមបែល* និង *គ្រេ* (Graham Bell & Grey) ជាតិអាមេរិកាំងបានបង្កើតទូរស័ព្ទក្នុងឆ្នាំ ១៨៧៦ ជាហេតុនាំឲ្យគេបំបាត់សញ្ញាណចំងាយទាំងឡាយ ។

### ក. វិវត្តន៍នៃរូបវិទ្យា

របកគំហើញថ្មីៗទៀតបានពង្រីកវិស័យរូបវិទ្យា បានធ្វើឲ្យទស្សនៈវិទ្យាសាស្ត្រនេះប្រែប្រួលព្រមជាមួយនោះ គឺបានផ្តល់ដល់អ្នកប្រាជ្ញទាំងឡាយនូវមធ្យោបាយថ្មីៗ សំរាប់សកម្មភាពរបស់គេ ។ ទាំងនេះជាកត្តាមួយសំរាប់ដោះស្រាយបញ្ហាអនាគត ។ នៅឆ្នាំ ១៨៩៥ លោក *រ៉ុនហ្កេន* (Roentgen) បានរកឃើញកំលាំងរស្មីអ៊ិច (rayon X) ដែលអាចឲ្យគេឆ្លុះមើលធ្លុះនូវវត្ថុធាតុរឹង ។ លោក *បិចគឺរ៉ែល* (Becquerel) ជាតិបារាំងបានរកឃើញក្នុងឆ្នាំ ១៨៩៦ នូវធាតុភូតវិទ្យុសកម្ម ។ ឯលោក និង លោកស្រី *គ្យូរី* (Curie) ជាភរិយាបានរកឃើញអង្គធាតុមួយមានវិទ្យុសកម្មដ៏ខ្លាំង គឺជាតិរ៉ាដ្យូម (radium) ។

ការសិក្សាអំពីវិទ្យុសកម្មបានធ្វើឲ្យគេស្គាល់មួយកំរិតថែមទៀត នូវធម្មជាតិនៃអង្គធាតុ ។



*លោក អាញ ស្តាញ (១៨៧៩ - ១៩៥៥)*

កិច្ចអនុវត្តរបកគំហើញទាំងនេះបានផ្តល់វិជ្ជាពេទ្យ នូវមធ្យោបាយទាំងឡាយ សំរាប់ធ្វើការពិនិត្យការសង្កេត និងសំរាប់សកម្មភាពទូទៅរបស់មនុស្ស ។

ដោយមានការលូតលាស់និងរីកចំរើនដ៏ឆាប់រហ័ស អ្នកប្រាជ្ញទាំងឡាយបានលើកមកសើរើពិនិត្យឡើងវិញនូវគោលនិយមសំខាន់ៗទាំងឡាយខាងរូបវិទ្យាក្នុងបច្ចុប្បន្នសម័យនេះ គេកំពុងតែបន្តការពិនិត្យពិសោធ អំពីទ្រឹស្តីដែលអ្នកប្រាជ្ញ អាឡឺម៉ង់បានរកឃើញពោល គឺ *ទ្រឹស្តីកង់តា* (Théorie des Quanta) និង *ទ្រឹស្តីរ៉ឺឡាទីវីតេ* (Théorie de la Relativité) របស់លោក *ប្លង់* និង លោក *អាញស្តាញ* (Planck & Einstein) ។

២. អំពីគីមីវិទ្យា

ការចំរើនខាងគីមីវិទ្យា មានភាពទាក់ទងយ៉ាងជិតស្និទ្ធនឹងការរីកចំរើនខាងរូបវិទ្យា ជាហេតុពុំអនុញ្ញាតឲ្យគេចែកវិទ្យាសាស្ត្រទាំងពីរនេះ ឲ្យដាច់ពីគ្នាបានឡើយ ។ របងដែលខ័ណ្ឌរូបវិទ្យាពីគីមីវិទ្យា ត្រូវបាត់បង់បន្តិចម្តងៗ ។ វិទ្យាសាស្ត្រមួយថ្មីក៏ត្រូវចាប់កំណើតដែរ គឺរូបវិទ្យាគីមី ។ ឯវិធីសាស្ត្រប្រើខាងរូបវិទ្យាក៏ត្រូវបានយកមកប្រើក្នុងគីមីវិទ្យាដែរ ។

លោក *ប៊ែតឺឡូ* (Berthelot) អ្នកប្រាជ្ញបារាំង បានវាស់ដោយទៀងទាត់នូវល្បឿនប្រតិកម្មគីមី និងបរិមាណកំដៅនៃប្រតិកម្មនេះ ព្រមទាំងបានបង្កើតវិទ្យាសាស្ត្រមួយថ្មីហៅ *ទែម៉ូគីមី* (thermochimie) ។ លោកបានដោះស្រាយបញ្ហាផ្សំអង្គធាតុ (synthèse des corps) ហើយដោយបានធ្វើពិសោធន៍បន្តៗមកទៀត លោកបានបង្ហាញ

ឲ្យឃើញថា គេអាចបង្កើតអង្គធាតុថ្មី ដោយវិធីផ្សំនេះ ដូចជាគេផ្សំ *ស្រា* ផ្សំ *អាសេទីឡែន* (acétylène) *បង់ហ្សែន* (benzène) ជាដើម នៅឆ្នាំ ១៨៤៥-១៨៦២ ។

ការចំរើនខាងគីមីវិទ្យាក៏ដូចជាខាងរូបវិទ្យាដែរ បាននាំមកនូវអនុវត្តន៍ជាច្រើនមានផលិតកម្មគីមីដូចជាតិគីមី ផលិតកម្មពេទ្យ វត្ថុជ្រលក់ពណ៌ ឬសូត្រឧស្សាហកម្ម ។ល។ គីមីវិទ្យាបានធ្វើឲ្យបច្ចេកទេសស្លដែកប្រែប្រួលជាច្រើន ព្រមទាំងបច្ចេកទេសសឹកផងដែរដូចជាការបង្កើតរំសេវ ឬខ្យល់ឈ្ពក់ ។



*លោក ប៊ែតឡូ (១៨២៧ - ១៩០៧)*

## គ. អំពីមីក្រុបវិទ្យា

លោក *ប៉ាស្ទ័រ* (Pasteur) បានយកវិធីពិសោធរបស់លោក *ក្លូតប៊ែណា* (Claude Bernard) មកប្រើ ហើយបានសំរេចស្នាដៃមួយដ៏សំខាន់ ដែលបានផ្ដល់ផលប្រយោជន៍មួយដ៏ធំដល់មនុស្សជាតិទូទៅ ។

លោក *ប៉ាស្ទ័រ* បានចេញពីសាលាគរុវិជ្ជាជាន់ខ្ពស់ ជាអ្នកគីមីម្នាក់ដ៏ជំនាញ បានសិក្សាយ៉ាងជ្រៅជ្រះអំពីការ *ឡើងពាយស្រា* (fermentation) ។ តាំងពីដើមរៀងដរាបមក មតិទូទៅបានទុកបាតុភូតនេះ ជាបាតុភូតខាងគីមី ។ លោកប៉ាស្ទ័របានរកឃើញ ព្រមទាំងបានបញ្ជាក់ថែមទៀតថា បាតុភូតខាងលើបណ្ដាលឡើងដោយសត្វល្អិតតូចៗហៅមីក្រុប ដែលរស់រានមានជីវិតក្នុងមជ្ឈដ្ឋានមួយ អនុគ្រោះដល់វា ។ ឯមីក្រុបនេះមានសណ្ឋានប្លែកៗគ្នា រស់ពាសពេញក្នុងធូលី និងខ្យល់អាកាស ។ មីក្រុបវិទ្យាក៏ចាប់កំណើតឡើង ហើយលោកប៉ាស្ទ័របានទាញយកលទ្ធផលជាក់ស្ដែងពីរបកគំហើញរបស់លោកភ្លាមៗដែរ ។ លោកបានចង្អុលឲ្យដឹងថា ដើម្បីកុំឲ្យវត្ថុនានាជារ គេត្រូវដុតភ្លើង ដើម្បី



*លោក ក្លូត ប៊ែណា (១៨១៣ - ១៨៧៨)*

សំលាប់មីក្រុបនេះ ។ គេបានយកវិធីនេះទៅអនុវត្តដើម្បីរក្សាទុកឲ្យបានយូរនូវស្រាទំពាំងបាយជូរ ស្រាបៀរ ទឹកដោះគោ និងគ្រប់វត្ថុផ្សេងៗទាំងឡាយ ។

### ឃ. ការរិះរកខាងជំងឺឆ្លង

ការរិះរកខាងជំងឺបានធ្វើឲ្យលោកប៉ាស្ទ័រមានកិត្តិនាមល្បីល្បាញក្នុងលោកទាំងមូល ។ នៅឆ្នាំ ១៨៦៥ លោកបានរកឃើញបុព្វហេតុជំងឺដង្កូវនាង ព្រមទាំងរកមធ្យោបាយមកកំចាត់ជំងឺនេះថែមទៀត ។ ក្រោយមក លោកបានរកឃើញមធ្យោបាយបង្ការអាសន្នរោគ រោគឆ្កែឆ្កួតខាំ ។ល។ ដោយរបកគំហើញនេះ លោកប៉ាស្ទ័រក៏ត្រូវសកលលោកទាំងមូលទទួលស្គាល់ថាជាអ្នកបានផ្ដល់ដល់មនុស្សជាតិទូទៅ នូវមនុញ្ញផលមួយដ៏ធំមហិមា ។ បន្ទាប់មក គេបានអង្គាសប្រាក់ពីគ្រប់មជ្ឈដ្ឋានអន្តរជាតិ ដើម្បីស្ថាបនាវិទ្យាស្ថានប៉ាស្ទ័រសំរាប់បន្តការសិក្សាអំពីជំងឺឆ្លងនេះ ។

លោកប៉ាស្ទ័របានទទួលអនិច្ចកម្មនៅឆ្នាំ ១៨៩៥ ។ សិស្សរបស់លោកបានព្យាយាមសិក្សាបន្តនូវរបកគំហើញរបស់លោក ហើយបានបង្កើតថ្នាំបង្ការរោគជាច្រើនទៀត ។ លោកវេជ្ជបណ្ឌិត *រ៉ូ* (Roux) បានរកឃើញថ្នាំបង្ការរោគខាន់ស្លាក់ ។ លោក *កាល់ម៉ែត* និង*គេរ៉ាំង* (Calmette & Guérin) បានរកឃើញថ្នាំបង្ការរោគរបេង ។ ម្យ៉ាងទៀត សមិទ្ធិប៉ាស្ទ័របានផ្ដល់ដល់ការវះកាត់នូវជំនួយមួយយ៉ាងសំខាន់ ដូចជាការប្រើថ្នាំសំលាប់មីក្រុប មុកុំឲ្យប្រួសក្លាយក្នុងការវះកាត់ផ្សេងៗ ។

ជាទីបំផុត របកគំហើញរបស់លោកប៉ាស្ទ័របានបង្កើតឲ្យមានវិធីបង្ការរោគមួយក្នុង

សង្គមដោយសហប្រតិបត្តិការរវាងប្រទេសនានា ដើម្បីប្រយុទ្ធនឹងជំងឺឆ្កែឆ្កួត ព្រមទាំងបំបាត់ឲ្យវិនាសជំងឺនេះ ។



លោកប៉ាស្ទ័រ (១៨២២ - ១៨៩៥)

## ៤. លោកដាវីននិង វិវត្តនិយម



លោក ដាវិន (១៨០៩-១៨៨២)

អ្នកប្រាជ្ញខាងធម្មជាតិវិទ្យា អង់គ្លេសម្នាក់បានបញ្ចេញទ្រឹស្តីមួយដែលជាទីចាប់អារម្មណ៍នៃអ្នកប្រាជ្ញទាំងឡាយនាសម័យនោះ ។ តាមទ្រឹស្តីរបស់លោក ដែលមានចែងក្នុងសៀវភៅមួយស្តីពី *«ដើមកំណើតនៃសត្វ»* លោកដាវិន បានអះអាងថា *«គ្រប់សត្វនិងគ្រប់រុក្ខជាតិទាំងអស់បានចាប់កំណើតមកតែពីសត្វ ឬរុក្ខជាតិបួនឬប្រាំប្រភេទប៉ុណ្ណោះ ឬក៏បានចាប់កំណើតមកតែពីប្រភេទមួយផង»* ។ ផ្ទុយពីមតិលោក *ឡាម៉ាក* (Lamarck) ដែលអះអាងថា «វិវត្តន៍នៃសត្វទាំងឡាយតែងប្រព្រឹត្តទៅតាមឥទ្ធិពលនៃមជ្ឈដ្ឋាន» លោកដាវិនបានបញ្ជាក់ថា វិវត្តន៍របស់សត្វបានសំរេចទៅតាមវិធីជ្រើសរើសធម្មជាតិ (sélection naturelle) ។ សត្វណាអន់ខ្សោយត្រូវស្លាប់សាបសូន្យនៅសល់តែសត្វណាដែលខ្លាំងពូកែ ។ សត្វខ្លាំងពូកែនេះក៏ចេះតែមានវិវត្តន៍រៀងរាបរហូតមក ពីឋានៈទាបទៅកាន់ឋានៈខ្ពស់ ។ ឯសត្វដែលឈានដល់ឋានៈខ្ពស់ជាងគេ គឺសត្វមនុស្សយើងនេះឯង ។

## ៥. ម៉ាស៊ីននិងអរិយធម៌វិទ្យាសាស្ត្រ

ជាមួយនឹងការចំរើនខាងវិទ្យាសាស្ត្រ អរិយធម៌បច្ចុប្បន្នក៏មានបំលាស់ប្តូរយ៉ាងឆាប់រហ័សដែរ ហើយអរិយធម៌នេះបានផ្អែកស្ទើរតែទាំងស្រុងទៅលើវិទ្យាសាស្ត្រ ។ បំលាស់ប្តូរបានប្រព្រឹត្តតាំងតែពីពាក់កណ្តាលសតវត្សទី ១៩ មកម៉្លេះ ជាពិសេសនៅចក្រភពអង់គ្លេសនិងនៅប្រទេសបារាំង ។ តែបំរែបំរួលនេះទើបតែមានដំណើរឆាប់រហ័ស ចាប់ពីឆ្នាំ ១៨៥០ រហូតមកទល់សព្វថ្ងៃ ។

លក្ខណៈទោលនៃអរិយធម៌វិទ្យាសាស្ត្របិតលើភាពសំបូរផាលំផាប់ ខាងថាមពលដែលវិទ្យាសាស្ត្របានផ្តល់ជាជំនួយដល់ការងាររបស់មនុស្ស ។ មនុស្សបានយកកំលាំងធម្មជាតិទាំងឡាយប្រើជំនួសកំលាំងកាយរបស់ខ្លួននិងកំលាំងសត្វ ។ ក្នុងករណីនេះ របកគំហើញដ៏មានសារៈសំខាន់ជាងគេគឺ

ក. ម៉ាស៊ីនប្រើកំលាំងចំហាយទឹក



*ពិធីសម្ពោធព្រែកជីកស៊ុយអេ (១៨៦៩)*

គេបានបង្កើតម៉ាស៊ីននេះ នៅចុងសតវត្សទី ១៨ នៅចក្រភពអង់គ្លេស ដោយប្រើធ្យូងថ្មសំរាប់ដុតយកចំហាយទឹក ។ ឧស្សាហកម្មធ្យូងថ្មក៏បានលូតលាស់យ៉ាងឆាប់រហ័ស (៩០ លានតោនក្នុងឆ្នាំ ១៨៥០ ២ ពាន់លានតោនក្នុងសម័យបច្ចុប្បន្ន) ។ នៅពាក់កណ្តាលទី ២ នៃសតវត្សទី ១៩ ម៉ាស៊ីនចំហាយទឹក និងធ្យូងថ្មបានធ្វើឲ្យមានបដិវត្តន៍ខាងការបង្កើតផល និងខាងការដឹកនាំទៀតផង ។ សព្វថ្ងៃ ម៉ាស៊ីនចំហាយទឹកនិងធ្យូងថ្មក៏នៅតែជាកត្តាសំខាន់ដដែលនៃសកម្មភាពនិងអានុភាពនៃសេដ្ឋកិច្ចរបស់រដ្ឋនីមួយៗ ។ ក៏ប៉ុន្តែ របកគំហើញថ្មីៗទៀតបានមកប្រកួតប្រជែងនឹងថាមពលនេះ គឺ*ថាមពលអគ្គិសនី* ។

ខ. ថាមពលអគ្គិសនី

គេអាចយកថាមពលនេះមកប្រើប្រាស់បានសព្វគ្រប់ ពិសេស ផ្លាស់ថាមពលមេកានិចឱ្យបានជាអគ្គិសនី ហើយយកថាមពលនេះទៅអនុវត្តការងារមេកានិចវិញ ។ ក្រោយមកទៀត គេអាចបង្កើតថាមពលអគ្គិសនីដោយប្រើកំលាំងល្បាក់ទឹក ។ ចាប់ពីពេលនោះមក ឧស្សាហកម្មវារីអគ្គិសនីក៏មានការលូតលាស់យ៉ាងឆាប់រហ័ស ។ ម្យ៉ាងទៀត គេអាចដឹកនាំថាមពលនេះបានស្រួល ហើយឆ្ងាយៗ ដោយការប្រើប្រាស់ចរន្តអគ្គិសនី ។ សព្វថ្ងៃ គេកំពុងតែរិះរកមធ្យោបាយប្រើថាមពលទឹកសមុទ្រ ដែលជាឃ្លាំងថាមពលមួយពុំមានវិងស្ងួតឡើយ ។

គ. ម៉ាស៊ីនផ្ទុះ

ការបង្កើតម៉ាស៊ីនផ្ទុះអាចឱ្យគេប្រើថាមពលដទៃទៀត ដូចជាប្រេងសាំង ម៉ាស៊ូត ។ល។ ម៉ាស៊ីនប្រើប្រេងសាំងនេះខ្លាំង ហើយស្រាលផង ជាម៉ាស៊ីនដ៏ប្រពៃសំរាប់រថយន្ត កប៉ាល់ហោះ ឬនាវា ។ល។ ឯផលិតផលខាងប្រេងកាតក្នុងលោកក៏បានលូតលាស់យ៉ាងឆាប់រហ័សដែរ (២ លានតោននៅឆ្នាំ ១៨៨០, ១៥០ លានតោននៅឆ្នាំ ១៩២៥) ។

ដោយសង្ខេប គេអាចសន្និដ្ឋានបានថា ធ្យូងថ្ម អគ្គិសនី និងប្រេងកាតជាប្រភពថាមពលដ៏សំខាន់ សំរាប់ធ្វើឱ្យម៉ាស៊ីនទាំងឡាយអនុវត្តគ្រប់កិច្ចការតាមបំណងមនុស្ស ។

បច្ចុប្បន្នកាលនេះ ថាមពលបរមាណូក៏ត្រូវគេយកមកប្រើខ្លះៗដែរ ដូចជានៅចក្រភពអង់គ្លេស សហរដ្ឋអាមេរិច និងសហភាពសាធារណរដ្ឋសង្គមនិយមសូវៀតជាដើម ។

ឃ. បច្ចេកទេសថ្មីខាងឧស្សាហកម្ម

ដោយការលូតលាស់នៃការប្រើប្រាស់ខាងម៉ាស៊ីន បច្ចេកទេសខាងឧស្សាហកម្មក៏មានវិវត្តន៍ច្រើនដែរ ។ ក្នុងវិស័យវាយនភណ្ឌ គេបានបង្កើតម៉ាស៊ីនត្បាញជំនួសកំលាំងមនុស្ស ។ បំណិននៃយន្តការីបានបង្កើតម៉ាស៊ីនគ្រប់បែបយ៉ាង ដែលអាចធ្វើការជំនួសកម្មករបានដោយងាយ ហើយឆាប់រហ័សទៀតផង ដូចជាម៉ាស៊ីនលើកដាក់ ម៉ាស៊ីនគិតលេខ ម៉ាស៊ីនចាប់អក្សរពុម្ព ។ ម្យ៉ាងទៀត វិទ្យាសាស្ត្រទាំងឡាយអនុញ្ញាតគេឱ្យច្នៃបច្ចេកទេសឧស្សាហកម្មឱ្យរឹតតែមានវិសិដ្ឋភាពឡើងទៀត ។ ក្នុងករណីនេះ ឧស្សាហកម្មគីមីមានការលូតលាស់ជាច្រើនដូចជាការធ្វើកៅស៊ូ សាប៊ូ ឬជ្រលក់ពណ៌ ជាពិសេសគឺ វិធីស្លដែកដែលអាចឱ្យគេទាញ

យកដែកពីរ៉ែបានដោយប្រើ វិធីថ្មីនេះ ។

### ង. បច្ចេកទេសថ្មីខាងកសិកម្ម

បច្ចេកទេសកសិកម្មក៏មានបដិវត្តន៍ដូចជាបច្ចេកទេសឧស្សាហកម្មដែរ ។ វិវត្តន៍នេះជាបច្ច័យនៃការលូតលាស់ចំរើននៃវិទ្យាសាស្រ្ត និងអនុវត្តន៍នូវរបកគំហើញថ្មីៗខាងគីមីវិទ្យា ។ ចាប់ពីសតវត្សទី ១៨ មក គេបានបង្កើតម៉ាស៊ីនថ្មីៗសំរាប់កិច្ចការកសិកម្ម មានម៉ាស៊ីនពោកបែនម៉ាស៊ីនសាបព្រោះ ម៉ាស៊ីនច្រូតកាត់ ។ល។ គេបានបង្កើតនង្គ័លម៉ាស៊ីនប្រើកំលាំង



*ម៉ាស៊ីនពោកស្រូវ (១៨៥៩)*

ចំហាយទឹក ប្រើអគ្គិសនី ឬប្រើប្រេងកាតជំនួសនង្គ័លទាញដោយសត្វពាហនៈ ជាហេតុអនុញ្ញាតគេឲ្យប្រកបកិច្ចការកសិកម្មបានឆាប់រហ័ស ហើយពុំសូវនឿយហត់ផង ។ ស្របជាមួយគ្នានេះ ដំណាំដាំដុះបានរីកចំរើន ហើយនៅប្រទេសខ្លះ គ្រប់កិច្ចការរបស់កសិករត្រូវធ្វើដោយម៉ាស៊ីនទាំងអស់ ចាប់ពីភ្ជួររាស់រហូតបានផលដាក់ជង្រុក ។

ម្យ៉ាងទៀត របកគំហើញជីជាតិគីមី ដូចជា ផូស្វាត ប៉ូតាស អាសូតអាចឲ្យគេទាញផលពីដីបានច្រើនជាងពេលមុនៗ ។

តាមធម្មតា នៅគ្រប់ប្រទេស កសិកម្មមានវិវត្តន៍យឺតយ៉ាវជាងឧស្សាហកម្ម ។ យ៉ាងណាមិញ កសិកម្មទាំងឡាយពុំសូវមានសេចក្តីទុកចិត្តលើបច្ចេកទេសថ្មីៗឡើយ លើកលែងតែ

នៅប្រទេសទាំងឡាយដែលមានការរៀបចំការសិក្សាបច្ចេកទេសល្អគួរ ដូចជានៅ *ផាណកីម៉ាក អាឡឺម៉ង់ អូស្ត្រាលី សហរដ្ឋអាមេរិច* និង*សហភាពសូវៀត* ជាដើម ។

ច. មធ្យោបាយគមនាគមន៍ និងដឹកនាំ

បំលាស់ប្តូរដែលធ្វើឲ្យលោកយើងសម័យនេះមានបំរែបំរួលច្រើនជាងគេ គឺការល្អគួរលាស់នៃមធ្យោបាយគមនាគមន៍ និងដឹកនាំ ។ យ៉ាងណាមិញ គេបានបង្កើតជាលំដាប់ៗ គ្នានូវកប៉ាល់ប្រើកំលាំងចំហាយទឹក ផ្លូវរទេះភ្លើង ទូរលេខ ទូរស័ព្ទ រថយន្ត យន្តហោះ វិទ្យុទូរលេខ ។ល។ ក្នុងសម័យដើម គេធ្វើដំណើរតាមដំរី សេះ រទេះ ឬរទេះសេះ ។ល។ ឯគ្រប់ទំនិញក៏ត្រូវដឹកនាំតាមមធ្យោបាយខាងលើនេះដែរ ។ ដំណើរបែបនេះយឺតយូរ នឿយហត់ ពុំបានឆ្ងាយ ហើយពុំសូវមានសន្តិសុខទៀតផង ។ តាមទឹក គេប្រើទូកក្តោងសំពៅ ។ល។

ឆ. ការពង្រីកផ្លូវរទេះភ្លើង

ពង្រីកផ្លូវរទេះភ្លើងជាស្នាដៃមួយយ៉ាងសំខាន់នៃសម័យបច្ចុប្បន្ន ។ ការស្ថាបនាផ្លូវដែកអាចប្រព្រឹត្តទៅបាន ក៏អាស្រ័យលើការល្អគួរលាស់ខាងឧស្សាហកម្មដែកដែរ ។ ប្រវែងផ្លូវដែកសរុបក្នុងលោក ក្នុងឆ្នាំ ១៨៥០ មានប្រមាណ ៣៨ ០០០ គ.ម. (អឺរ៉ុបមាន ២៣ ០០០ គ.ម.) ។ ២០ ឆ្នាំក្រោយមក គឺនៅឆ្នាំ ១៨៧០ ប្រវែងនេះបានកើនដល់ ២០០ ០០០ គ.ម. ហើយ ៤០ ឆ្នាំក្រោយមកទៀត មានដល់ទៅជាង ១ លាន គ.ម. (សហរដ្ឋអាមេរិច ៤០០ ០០០ គ.ម. អាស៊ី ១០០ ០០០ គ.ម.) ។

ជ. ការល្អគួរលាស់ខាងនាវាចរសមុទ្រ

ជាមួយនឹងការល្អគួរលាស់ខាងផ្លូវគោក នាវាចរសមុទ្រក៏ល្អគួរលាស់យ៉ាងឆាប់រហ័សណាស់ដែរ ជាហេតុនាំឲ្យចរន្តចរាចរណ៍ក្នុងលោកមានសកម្មភាពជានិរន្តរ៍ ។ បន្តិចម្តងៗ ទំហំកប៉ាល់ កំលាំងម៉ាស៊ីនបានរីកចំរើនជាលំដាប់ ស្របជាមួយនឹងការល្អគួរលាស់ខាងចរាចរណ៍និងពាណិជ្ជកម្ម ។ កាលពីពាក់កណ្តាលសតវត្សទី ១៩ កប៉ាល់ធំជាងគេដឹកបានតែ ៧០ នាក់ប៉ុណ្ណោះ ហើយមានចំណុះប្រមាណ ១ ៨០០ តោន ។ សព្វថ្ងៃ កប៉ាល់ធំៗមានចំណុះពី ៤ ម៉ឺនទៅ ៨ ម៉ឺនតោន អាចដឹកមនុស្សបានពី ២ ពាន់ទៅ 6 ពាន់នាក់ ហើយមានកំលាំងអូសពី ៥ ម៉ឺនទៅ ៨ ម៉ឺនសេះ និងល្បឿនពី ៥០ ទៅ ២៧០ គ.ម. ក្នុងមួយម៉ោង ។

នាវាសមុទ្រធំៗ បានដឹកនាំមនុស្សនិងទំនិញពីទ្វីបមួយទៅទ្វីបមួយទៀតប្រកបដោយផាសុកភាពនិងសន្តិសុខពេញលេញទៀតផង ។ ម្យ៉ាងទៀត គេអាចបំប្រួញផ្លូវថែមទៀត ដោយការជីកព្រែកផ្សេងៗ ដូចជាព្រែកជីកស៊ុយអេ (១៨៦៩) ព្រែកជីកគៀល (១៨៩៥) ព្រែកជីកប៉ាណាម៉ា (១៩១៤) ជាដើម ។

ឈ. មធ្យោបាយដឹកនាំថ្មី

មកទល់នឹងដើមសតវត្សទី ២០ មានតែផ្លូវដែកនិងនាវាសមុទ្រទេ ដែលជាមធ្យោបាយដឹកនាំឆាប់រហ័ស ។ ការលូតលាស់ចំរើនពុំឈប់ឈរខាងវិទ្យាសាស្ត្រ ខាងម៉ាស៊ីននិងខាងឧស្សាហកម្មបានអនុញ្ញាតគេឲ្យបង្កើតមធ្យោបាយថ្មីៗទៀតសំរាប់ដឹកនាំ ។




*រថយន្ត រត់ពីប៉ារីសទៅប៊ែឡាំង (២៧ មិថុនា ១៩០១)*

បន្ទាប់ពីជោគជ័យនៃរទេះភ្លើង ចរាចរណ៍ខាងផ្លូវថ្នល់មានសកម្មភាពរឹតតែរស់រវើកមួយកំរិត

ទៀតដោយការបង្កើតរថយន្ត ។ រថយន្តអាចឲ្យគេធ្វើដំណើរបានលឿន ឆ្ងាយ ហើយឆាប់រហ័សទៀតផង ។ ឯចំនួនរថយន្តបានកើនយ៉ាងឆាប់រហ័ស ( នៅប្រទេសបារាំងរថយន្តកើនពី ៥០០ ក្នុងឆ្នាំ ១៨៩៣ ដល់ ២០០ ០០០ ក្នុងឆ្នាំ ១៩២៧ ) ។ សហរដ្ឋអាមេរិចមានរថយន្តចំនួន ២២ លាន គឺរថយន្តមួយក្នុងមនុស្ស ៥ នាក់ ។

ការប្រើប្រាស់រថយន្តទើបតែនឹងចាប់ផ្ដើមនៅឡើយ ប៉ុន្តែបន្តិចម្ដងៗ រថយន្តបានជំនួសរទេះអូសដោយសត្វស្ទើរតែនៅគ្រប់កន្លែង ។ ក្នុងក្រុងធំៗ គេពុំប្រទះឃើញរទេះប្រើកំលាំងសត្វទៀតឡើយ ដូចជាក្រុងប៉ារី ញូយ៉ក ឡុង ម៉ូស្គូ ។

តាមសមុទ្រ ក្រៅពីនាវាដើរដោយកំលាំងចំហាយទឹកគេបានបង្កើតនាវាប្រើកំលាំងប្រេងកាតឬម៉ាស៊ីនអគ្គិសនី ។ ក្នុងឆ្នាំ ១៨៨៥ - ១៨៩០ គេបានបង្កើតកប៉ាល់មុជទឹកថែមទៀត ។

៣ . ការដឹកនាំតាមអាកាស

ក្នុងសម័យជាមួយគ្នានេះ គឺនៅដើមសតវត្សទី ២០ គេបានបង្កើតយន្តហោះសំរាប់ដឹកនាំតាមអាកាស ។ ក្រោយពីបដិវត្តន៍យ៉ាងឆាប់រហ័ស យន្តហោះក៏មានបំរែបំរួលវិវត្តឆ្ពោះទៅរកការចំរើនដ៏ស្ញប់ស្ញែងដែរ ។ សព្វថ្ងៃនេះ យន្តហោះធំៗអាចដឹកមនុស្សបានពី ១០០ ទៅ ៣០០ នាក់ មានល្បឿនប្រមាណ ១ ០០០ គ.ម. ក្នុងមួយម៉ោង ហើយភ្ជាប់ប្រទេសមួយទៅប្រទេសមួយទៀត ក្នុងរយៈពេលដ៏ខ្លី ។



*បាឡុងហោះមួយ (១៩១០)*

ជ. មធ្យោបាយទាក់ទងគ្នា

ក្រសួងប្រៃសណីយ៍បានទទួលផលជាច្រើនពីការចំរើននៃគ្រប់មធ្យោបាយដឹកនាំ ។ ម្យ៉ាងទៀត កំលាំងអគ្គិសនីបានផ្តល់មធ្យោបាយទាក់ទងគ្នា ដោយពុំចង់ពឹងផ្អែកទៅលើដំណឹកនាំឡើយ ។ នៅឆ្នាំ ១៨៣៣ គេបានបង្កើតទូរលេខអគ្គិសនី និងនៅឆ្នាំ ១៨៧៧ គេបានបង្កើតទូរស័ព្ទ ជាហេតុអាចឲ្យគេទាក់ទងគ្នាបានភ្លាមៗ ទោះបីនៅឆ្ងាយពីគ្នាយ៉ាងណាក៏ដោយ ។ ការភ្ជាប់ទ្វីបមួយទៅទ្វីបមួយ ដោយប្រើខ្សែលួសបង្កប់ក្នុងបាតសមុទ្រឬមហាសមុទ្រ អាចធ្វើឲ្យគេទាក់ទងគ្នាបានឥតប់ក្រៃលែង ។ ការបង្កើតទូរស័ព្ទឥតខ្សែនៅឆ្នាំ ១៩០៦ មានសារៈសំខាន់ជាទីបំផុត ។

ម៉្យាងគឺអាចឲ្យនាវាក្នុងមហាសមុទ្រឬយន្តហោះក្នុងអាកាសទាក់ទងជាអចិន្ត្រៃយ៍ជាមួយនឹងស្ថានីយនៅលើដី ជាហេតុអាចឲ្យគេចៀសវាងគ្រោះថ្នាក់បាន ។ ម៉្យាងទៀត ទូរស័ព្ទឥតខ្សែអាចឲ្យគេស្តាប់ពីគ្រប់ទិសទីក្នុងលោក ជាហេតុអាចឲ្យគេចូលរួមក្នុងព្រឹត្តិការណ៍ប្រចាំថ្ងៃបានដោយងាយ ។ គេអាចសន្និដ្ឋានបានថា ទូរស័ព្ទឥតខ្សែជាមធ្យោបាយគមនាគមន៍មួយដ៏សំខាន់សំរាប់ញាំងមនុស្សទាំងឡាយឲ្យរឹតតែស្គាល់គ្នាដ៏ជិតស្និទ្ធថែមទៀត ។



*អ្នកបើកយន្តហោះបារាំងម្នាក់ឈ្មោះប្លេរ្យ៉ូ (១៩០៩)*

## សំណួរ

១. ហេតុអ្វីបានជាគេសន្និដ្ឋានថា សម័យបច្ចុប្បន្នជាសម័យនៃអរិយធម៌វិទ្យាសាស្ត្រ ?

២. ការចំរើនខាងវិទ្យាសាស្ត្រអាចសំរេចបានឆាប់រហ័សដោយអាស្រ័យលើអ្វីខ្លះ ?

៣. រៀបរាប់អំពីរបកគំហើញសំខាន់ៗខាងវិទ្យាសាស្ត្រ ។

៤. ហេតុអ្វីបានជាគេចាត់ទុកលោក *ប៉ាស្ទ័រ* ថាជាអ្នកបានផ្តល់ជូនមនុស្សជាតិ នូវមនុញ្ញផលដ៏សំខាន់ ?

៥. លក្ខណៈសំខាន់នៃអរិយធម៌វិទ្យាសាស្ត្របិតលើអ្វី ?
រៀបរាប់អំពីថាមពលថ្មីៗដែលវិទ្យាសាស្ត្របានផ្តល់ដល់មនុស្ស ។

៦. ការបញ្ចូលបច្ចេកទេសថ្មីខាងឧស្សាហកម្មនិងខាងកសិកម្មមានឥទ្ធិពលលើសកម្មភាពដូចម្តេចខ្លះ ?

៧. រៀបរាប់អំពីមធ្យោបាយថ្មីៗខាងដំណើកនាំ និងគមនាគមន៍ ។ មធ្យោបាយទាំងនេះមានប្រយោជន៍អ្វីខ្លះ ?

# ២. ចលនាគំនិត អក្សរសាស្ត្រ និងសិល្បៈ នៅសតវត្ស ទី ១៩ និង ទី ២០

## ១. លក្ខណៈទូទៅ

សកម្មភាពខាងបញ្ញានាសម័យបច្ចុប្បន្នបានទទួលឥទ្ធិពលយ៉ាងច្រើនពីបរិវត្តន៍ចំលាស់ ឬខាងវិស័យសេដ្ឋកិច្ច នយោបាយ និងសង្គម ។ វិវត្តន៍ពីរដ៏សំខាន់ក្នុងនេះ គឺការចំរើនខាងវិទ្យាសាស្ត្រ និងការចំរើនខាងលទ្ធិប្រជាធិបតេយ្យ ។ យើងបានដឹងហើយថា វិទ្យាសាស្ត្រជាមូលដ្ឋាននៃអរិយធម៌នាលោកយើងសព្វថ្ងៃនេះ ។ យ៉ាងណាមិញ វិទ្យាសាស្ត្របានផ្តល់ដល់នាដករនូវបច្ចេកទេសថ្មីៗ ដល់អ្នកប្រាជ្ញកវីនិពន្ធ នូវទស្សនៈនិងវិធីការងារថ្មីៗទៀត ពោលគឺបានផ្តល់ដល់ទាំងអស់គ្នានូវប្រភពថ្មីៗសំរាប់ស្រង់យកធ្វើជាកម្មវត្ថុនៃការរិះគិត ។

ការរីកចំរើនខាងលទ្ធិប្រជាធិបតេយ្យក៏មានឥទ្ធិពលខ្លាំងណាស់ដែរ ។ គ្រប់ប្រទេសដែលមានអរិយធម៌ជឿនលឿន បានបញ្ចូលការបោះឆ្នោតជាសកល និងការសិក្សាជាសកល ជាហេតុនាំឲ្យមានមនុស្សចេះអក្សរច្រើន ។ ចំនួនមនុស្សចេះអានសៀវភៅ កាសែត ឬទស្សនាវដ្តី ចំនួនទស្សនិកជនខាងល្ខោន ភាពយន្ត ចំនួនមនុស្សទៅទស្សនាសារមន្ទីរ ពិព័រណ៍ ។ល។ បានកើនឡើងច្រើនឥតឧបមា ។ ទាំងនេះជាកត្តាមួយនៃការលូតលាស់ខាងអក្សរសាស្ត្រ ។ យ៉ាងណាមិញ មានអ្នកចេះអានច្រើន គេត្រូវតែផ្តល់ដល់សាធារណជនទាំងនោះ នូវសៀវភៅ កាសែត ទស្សនាវដ្តីគ្រប់បែបយ៉ាងដូច្នោះដែរ ។

## ២. គំនិតនិងស្នាដៃផ្សេងៗ

គេដឹងហើយថា សម័យមុនគឺជាសម័យនៃចលនាប្រលោមនិយម ( mouvement romantique ) ។ តែសម័យនេះជាសម័យមួយប្រកបទៅដោយចលនាគំនិតផ្សេងៗ ប្លែកៗគ្នាជាច្រើនទៅតាមនិន្នាការ ទៅតាមសាលា ទៅតាមស្នាដៃ ។ ក្នុងវិស័យនេះ គេចាត់ទុក

ប្រទេសបារាំងជាប្រទេសរៀមច្បង ។ តែក្រៅពីប្រទេសបារាំង មានប្រទេសឯទៀតជាច្រើនដែលចលនាគំនិតនេះបានចូលជ្រួតជ្រាបដល់អ្នកប្រាជ្ញវិបណ្ឌិតដែរ ដូចជាប្រទេសស្កង់ឌីណាវី ប្រទេសស្លាវ ពិសេសគឺប្រទេសរូស៊ី ។

ក្នុងពិភពលោក ចលនាប្តូរគ្នាទៅវិញទៅមកបានរីកចំរើនរវាងគ្រប់ប្រទេសនានា ជាហេតុអាចឱ្យគេសន្និដ្ឋានបានថា ជីវភាពខាងបញ្ញា ក៏ដូចជាជីវភាពខាងសេដ្ឋកិច្ច និងនយោបាយដែរគឺមានលក្ខណៈជាអន្តរជាតិ ។

## ៣ . លទ្ធិខាងទស្សនវិជ្ជានិងខាងសង្គម

### ក . ចលនាសំខាន់ៗខាងទស្សនវិជ្ជា

ការលូតលាស់នៃវិទ្យាសាស្ត្រជាប្រភពដ៏សំខាន់នៃបំលាស់ប្តូរខាងទស្សនវិជ្ជា ។ ក្នុងវិស័យទស្សនវិជ្ជានេះ គេឃើញមានចលនាពីរដែលមានន័យផ្ទុយគ្នាស្រលះ :

– មួយគឺលទ្ធិដែលផ្អែកទៅលើវិទ្យាសាស្ត្រ ។ គំនិតនេះបានត្រូវផ្សាយពាសពេញយ៉ាងឆាប់រហ័ស ។ ឯទស្សនវិទូល្បីល្បាញឈ្មោះជាងគេមានលោក *រឺណង់* ( Renan ) ពិសេសគឺលោក *ហឺបឺត ស្ពិនសឺ* ( Herbert Spencer ) ដែលបានស្ថាបនាប្រព័ន្ធទស្សនវិជ្ជា ( système philosophique ) ដោយផ្អែកលើគំនិតវិវត្តនិយម ។ ទស្សនៈនៃវិទ្យាសាស្ត្រនិយម ថ្វីបើមានការជំទាស់ពីសំណាក់អ្នកប្រាជ្ញឯទៀតៗជាច្រើន ក៏បានលូតលាស់ដល់ដើមសតវត្សទី ២០ យើងនេះ ។

– ពីរគឺចលនា *បដិវិទ្យាសាស្ត្រនិយម* ដែលជាប្រតិកម្ម ប្រឆាំងនឹងលទ្ធិដែលផ្អែកលើវិទ្យាសាស្ត្រ ។ លោក *ពង់ការេ* ( Poincaré) ដែលជាអ្នកគណិតវិទ្យាមួយរូបដ៏ល្បីល្បាញនិងជាតំណាងបដិវិទ្យាសាស្ត្រនិយម បានអះអាងក្នុងសៀវភៅមួយដែលលោកសរសេរនៅឆ្នាំ ១៩០៦ អំពី « តំលៃនៃវិទ្យាសាស្ត្រ » ថា គេពុំអាចបដិសេធតំលៃវិទ្យាសាស្ត្រក៏ពិតមែនហើយ ប៉ុន្តែវិទ្យាសាស្ត្រពុំអាចចាប់សច្ចៈបានទាំងអស់ឡើយ ។ រវាងវិទ្យាសាស្ត្រនិងអស្តិរូបនិយម ត្រូវមានរបាំងមួយដែលវិទ្យាសាស្ត្រពុំអាចឆ្លងកាត់បាន ហើយមានតែសហជញ្ញាណទេ ដែលឆ្លងកាត់បាន ដើម្បីចាប់យកសច្ចៈ ។ ចលនាបដិវិទ្យាសាស្ត្រនិយមមានអ្នកគាំទ្រជាច្រើន ជាពិសេសគឺលោក *ប៊ែរស៊ុន* ( Bergson ) ដែលបានអះអាងថា « វិទ្យាសាស្ត្រដែលជាស្ថាបត្យកម្មនៃបញ្ញា » ពុំអាចចាប់យកសច្ចៈបាន ដូចជាពេល

ចលនភាព វិវត្តនាការ (écoulement) ។ ដើម្បីយកសញ្ញាណទាំងនេះ គេត្រូវប្រើសហជញ្ញាណ ។

### ខ. ចិត្តវិទ្យាពិសោធនិងសង្គមវិទ្យា

ឥទ្ធិពលនៃវិទ្យាសាស្ត្រទៅលើទស្សនវិជ្ជា ដែលជាលក្ខណៈពិសេសនាសម័យបច្ចុប្បន្ន មិនមែនមានបាតុភាពតែទៅលើវិវត្តន៍នៃលទ្ធិទាំងឡាយនេះឡើយ គឺបានធ្វើឲ្យមែកធាងខ្លះនៃទស្សនវិជ្ជា ប្រែក្លាយទៅជាវិទ្យាសាស្ត្រ ដូចជា *ចិត្តវិទ្យា* និង *សង្គមវិទ្យា* ដែលពីដើមរៀងមក គេទុកដូចជាផ្នែកមួយនៃទស្សនវិជ្ជាដែរ ។ លុះមកដល់ពាក់កណ្តាលសតវត្សទី ១៩ *ចិត្តវិទ្យាពិសោធ* ក៏បានចាប់កំណើតដោយស្នាដៃអ្នកប្រាជ្ញទាំងឡាយដូចជាលោក *ហ្វិចន៊ែ* (Fechner) លោក *វុន* (Wundt) និងលោក *រីបូ* (Ribot) ជាដើម ។

ចរន្តគំនិត និងការស្រាវជ្រាវខាងលើបានបង្កើតវិទ្យាសាស្ត្រមួយថ្មីទៀត គឺ *សង្គមវិទ្យា* ដែលលោក *អូគុស្តកុង* (A. Comte) ជាអ្នកផ្តើមគំនិត ។ ក្រោយទៀតលោក *ស្ពិនសឺ* និងលោក *ឌួកហែម* (Durkheim) បានបន្តសកម្មភាពរបស់លោក *កុង* ហើយបានធ្វើឲ្យសង្គមវិទ្យាមានលក្ខណៈវិសេសវិសាលថែមទៀត ។

### គ. លទ្ធិសង្គមនិយមរបស់លោក កាលម៉ាក

លទ្ធិខាងសេដ្ឋកិច្ចនិងសង្គមមានវិវត្តន៍ដូចជាលទ្ធិខាងទស្សនវិជ្ជាដែរ ដោយទទួលឥទ្ធិពល ពីវិទ្យាសាស្ត្រ ។ លោក *កាលម៉ាក* ជាអ្នកប្រាជ្ញ ដែលបានបង្ហាញមុនគេបង្អស់នូវលទ្ធិសង្គមនិយម ។ លោកបានសិក្សាយ៉ាងម៉ត់ចត់ អំពីរបបមូលធននិយម ហើយបានសន្និដ្ឋានថា របបមូលធននិយមនេះ ដែលផ្អែកទៅលើសេរីភាពខាងប្រកួតប្រណាំង សេរីភាពខាងសហគ្រាស និងឧបករណ៍សំរាប់



*លោក កាលម៉ាក (១៨១៨-១៨៨៣)*

បង្កើតផលទាំងឡាយ ជាសម្បត្តិឯកជនម្នាក់ៗនោះ របបនេះមិនអាចលូតលាស់ឆាប់រហ័សឬចៀសវាងវិបត្តិសេដ្ឋកិច្ចបានឡើយ ។ ជាចុងក្រោយបង្អស់ លោកបានបន្ថែមថា របបមូលធននិយមជាប្រភពនៃចំបាំងរវាងប្រជាជាតិនានា ជាប្រភពនៃភាពគ្មានការធ្វើ ជាប្រភពនៃសេចក្តីក្រលំបាកតោកយ៉ាកនៃវណ្ណៈកម្មករ ។ល។

លោកបានអះអាងថា វិវត្តន៍ប្រវត្តិវិទ្យាមិនមែនសំរេចទៅតាមវិវត្តន៍នៃគំនិតឡើយ ។ វិវត្តន៍នេះជាលទ្ធផលនៃវិវត្តន៍ខាងលក្ខណៈជីវភាពសេដ្ឋកិច្ច ពិសេស គឺបច្ចេកទេសខាងការបង្កើតផលនេះឯង ។ ចំពោះលោក ម៉ាក លោកបានបញ្ជាក់ថា ច្បាប់ក្តី នយោបាយក្តី សីលវិជ្ជាក្តី សាសនាក្តី សិល្បៈក្តី វាគ្រាន់តែជាស្រមោលនៃការជាក់ស្តែងខាងសេដ្ឋកិច្ចប៉ុណ្ណោះ ។

លទ្ធិសង្គមនិយមដែលជាស្នាដៃរបស់លោក បានចាប់កំណើតតាំងពីពេលនោះមក ហើយបានរាលដាលពាសពេញសកលលោកយើងទាំងមូលយ៉ាងឆាប់រហ័ស ដែលគេហៅថាលទ្ធិម៉ាកនិយម ។

## ៤. ចលនាខាងអក្សរសាស្ត្រ

### ក. ដើមកំណើតនៃប្រាកដនិយម

ក្រោយឆ្នាំ ១៨៤៨ ប្រលោមនិយមដែលផ្អែកតែទៅលើមនោគតិ ទៅលើអារម្មណ៍ ទៅលើសញ្ចេតនាហួសហេតុពេកនោះ ត្រូវកវីនិពន្ធទាំងឡាយរិះគន់ជាច្រើន ហើយក៏ត្រូវតែសាបសូន្យបន្តិចម្តងៗតាំងពីពេលនោះមក ។

ចលនាអក្សរសាស្ត្រមួយថ្មីបានចាប់កំណើត គឺ *ប្រាកដនិយម* ( réalisme ) ពោលគឺចលនាវិទ្យាសាស្ត្រថ្មីនេះបានចាប់បដិសន្ធិស្របទៅតាមកាលៈទេសៈនៃប្រវត្តិសាស្ត្រ និងមជ្ឈដ្ឋាន ព្រមទាំងលទ្ធិថ្មីទាំងឡាយខាងទស្សនៈ និងខាងសេដ្ឋកិច្ច ។ យ៉ាងណាមិញ ការចំរើនខាងវិទ្យាសាស្ត្រ ខាងឧស្សាហកម្ម បំលាស់ប្តូរយ៉ាងឆាប់រហ័សនៃជីវភាពសេដ្ឋកិច្ច ហើយនិងឥទ្ធិពលនៃបំលាស់ប្តូរទាំងនេះបានបង្កើនជាលំដាប់ នូវធនធាននៃវណ្ណៈអ្នកដឹកនាំ និងបង្កើតទុគ៌តភាពនៃវណ្ណៈពលករ ។ ទាំងនេះជាប្រភពនាំឲ្យមានចលនាអក្សរសាស្ត្រថ្មី ។

## ខ. លក្ខណៈនៃប្រាកដនិយម

អ្នកប្រាជ្ញជាតំណាងចលនាអក្សរសាស្ត្រថ្មីនេះមានលក្ខណៈសំខាន់ដូចៗគ្នា : ការសង្កេតការពិតយ៉ាងម៉ត់ចត់ ពិតប្រាកដ ហើយត្រឹមត្រូវ ផ្ទុយពីប្រលោមនិយមដែលផ្តេកតែទៅលើការយល់សប្តិ ទៅលើសញ្ចេតនា ទៅលើអារម្មណ៍ ទៅលើភាពវើរវាយ ដែលច្រើនតែប្រាសចាកការជាក់ស្តែង ការពិត ។

ប្រាកដនិយមខាងសិល្បៈបានយកវិធីវិទ្យាសាស្ត្រមកប្រើ ដើម្បីនិពន្ធរឿងអ្វីមួយៗ ដូចជាអ្នកប្រវត្តិវិទ្យា ឬអ្នកធម្មជាតិវិទ្យាដូច្នោះដែរ ។

កវីនិពន្ធខាងសិល្បៈប្រាកដនិយមបានអះអាងថា សិល្បករមិនត្រូវបញ្ចេញបុគ្គលិកលក្ខណៈរបស់ខ្លួន ឲ្យចូលទៅក្នុងស្នាដៃរបស់ខ្លួនឡើយ ។

## គ. ធម្មជាតិនិយម (naturalisme)

ប្រាកដនិយម ក្រោយពីបានទទួលជោគជ័យ ក៏មានវិវត្តន៍ឆ្ពោះទៅរកចលនាមួយថ្មីទៀតគឺធម្មជាតិនិយមដោយសារឥទ្ធិពលនៃអ្នកប្រាជ្ញដ៏ល្បីល្បាញពីររូប គឺលោក *ក្លូត ប៊ែណា* (Claude Bernard) និងលោក *តែន* (Taine) ។

អ្នកនិពន្ធប្រាកដនិយមមានគោលបំណងនឹងផ្តល់ដល់សាធារណជននូវ «ជីវភាព» ពិតប្រាកដរបស់សង្គមមនុស្ស ពោលគឺសរសេរការពិតដែលខ្លួនបានដកស្រង់ពីជីវភាពរស់នៅសព្វថ្ងៃដូចជាល្អថាល្អ អាក្រក់ថាអាក្រក់ ខុសថាខុស ត្រូវថាត្រូវ ទុក្ខវេទនាថាទុក្ខវេទនា សុខសាន្ត ថាសុខសាន្ត ។ ចំពោះអ្នកនិពន្ធធម្មជាតិនិយមវិញ គេមាននិន្នាការនិងលក្ខណៈពិតហួសហេតុជាងប្រាកដនិយមទៅទៀត ។ ចលនាធម្មជាតិនិយមគឺចលនាវិទ្យាសាស្ត្រក្នុងអក្សរសាស្ត្រនេះឯង ។ លោក *អេមីលស៊ូឡា* (Emile Zola) បាននិយាយថា «ប្រលោមនិយមពិសោធជាបច្ច័យនៃវិវត្តន៍ខាងវិទ្យាសាស្ត្រ ក្នុងសតវត្សយើងនេះ» ។ យ៉ាងណាមិញ អ្នកនិពន្ធប្រលោមនិយមជាអ្នកសង្កេតផង ជាអ្នកពិសោធផង ។ អ្នកសង្កេតមានភារៈប្រមូលគ្រប់បាតុភូត ដែលខ្លួនពិនិត្យយ៉ាងច្បាស់លាស់ មកធ្វើជាមូលដ្ឋានសំរាប់រៀបចំតួរឿង ។ ឯអ្នកពិសោធវិញបានធ្វើឲ្យតួអង្គទាំងនេះ មានចលនាក្នុងប្រវត្តិដោយឡែកមួយ ដើម្បីបង្ហាញឲ្យឃើញថា បាតុភូតទាំងនេះមានចលនា

តៗគ្នា ដូចជាហេតុនិងផលដូច្នោះដែរ ។

ឃ. ឥទ្ធិពលនិងនិន្នាការថ្មីៗទៀត

ក្បួននិយម (dogmatisme) ខាងលើនេះបានបង្កើតឲ្យមានប្រតិកម្មមួយពីសំណាក់កវីក្នុងសម័យនោះ ដែលបានទទួលឥទ្ធិពលពីកវីនិពន្ធឯទៀតៗជាច្រើន ដូចជាអ្នកនិពន្ធ អ្នកប្រាជ្ញធំៗនៃប្រទេសរូស៊ី *ដុស្តូយេវស្គី* (Dostoïevsky) *តុលស្តូយ* (Tolstoï) ។ ស្នាដៃ



*លោក តុល ស្តូយ (១៨២៨-១៩១០)*

របស់អ្នកប្រាជ្ញទាំងពីររូបនេះដែលប្រកបទៅដោយប្រាកដនិយម ជាស្នាដៃជ្រួតជ្រាប ទៅដោយមនុស្សធម៌ សប្បុរសធម៌ មេត្តានិងករុណាដ៏ខ្ពង់ខ្ពស់ក្រៃលែង ។ ឥទ្ធិពលនៃអ្នកប្រាជ្ញឯទៀតៗក៏មានច្រើនដែរ ដូចជាអ្នកភ្លេងអាល្លឺម៉ង់ឈ្មោះ *វ៉ាកន័រ* (Wagner) កវីជាតិណរវែសឈ្មោះ *អ៊ីបសេន* (Ibsen) ជាតិអង់គ្លេសឈ្មោះ *គីព្លិញ* (Kipling) ជាតិអ៊ីតាលី ឈ្មោះ *ដានុនស្យូ* (d'Annunzio) ជាដើម ។

បន្ទាប់ពីចលនាធម្មជាតិនិយម គេឃើញមាននិន្នាការថ្មីៗទៀត ដែលបានចាប់កំណើតក្នុងរយៈកាលដ៏ខ្លី ។ ក្នុងចលនានេះ គឺមានចលនា *និមិត្តរូបនិយម* (symbolisme) ។ លក្ខណៈពិសេសនៃអក្សរសាស្ត្រមុនសង្គ្រាមលោកលើកទី ១ គឺបិតនៅលើការយកចិត្តទុកដាក់នៃអ្នកប្រាជ្ញចំពោះបញ្ហាសង្គម បញ្ហាសីលធម៌និងបញ្ហាសាសនា ពោលគឺអក្សរសាស្ត្រប្រែក្លាយទៅជាឧបករណ៍ដឹកនាំមួយយ៉ាងសំខាន់ ។

ចលនាអក្សរសាស្ត្រទាំងឡាយ ដែលយើងបានឃើញដោយអន្ទើមកហើយនេះ តែងមានបាតុភាពចេញជារូបរាងក្នុង :

– *រឿងប្រលោមលោក* ដែលរហូតមកដល់សព្វថ្ងៃនេះ បានលូតលាស់យ៉ាងសំបើម ដោយសាធារណជននិយមអានរឿងនេះណាស់ ។ លោក *ផ្លូបែ* (Flaubert ១៨២១-១៨៨០) ជាអ្នកជំនាញម្នាក់ក្នុងការនិពន្ធប្រលោមលោកបែបប្រាកដនិយម ។ ស្នាដៃរបស់លោកមាន «*អ្នកស្រីបូវ៉ារី*» ដែលបានទទួលជោគជ័យយ៉ាងច្រើន ។ ចំពោះកវីនិពន្ធប្រាកដនិយមឯទៀតៗ មានលោក *ទួកេញេវ* (Tourgueniev) *ដូស្តូយេវស្គី* *តុលស្តូយ* (រូស៊ី) *សាកអេល្យ៉ូ* (អង់គ្លេស) *អាល់ផុងដូដេ*



*លោកវិចទរ អ៊ុយហ្គោ (១៨០២-១៨៨៥)*

*គុយដឺម៉ូប៉ាសង់* ( បារាំង ) ដែលគេចាត់ទុកជាអ្នកសរសេរប្រលោមលោកល្បីល្បាញ ៗ

– *ល្ខោន* នាសម័យបច្ចុប្បន្នក៏បានទទួលពីសាធារណជន នូវចំណូលចិត្តច្រើន ដូចប្រលោមលោកដែរ ៗ អ្នករៀបរៀងរឿងដ៏ល្បីល្បាញមានលោក *អេមីលអូស្សេ* ( E.Augier ១៨២០ - ១៨៨៩ ) លោក *អាឡិចសង់ឌុយម៉ាស* ( កូន ) ( Alexandre Dumas fils ) ។ល។

– *កំណាព្យកាព្យឃ្លោង*

កវីដ៏ល្បីល្បាញជាងគេ ដែលប្រកបទៅដោយគំនិតប្រាកដនិយម មានលោក *វិចទ័រអ៊ុយហ្គោ* (Victor Hugo) *ឡឺកុងដឺលីល* ( Leconte de Lisle ១៨២០ - ១៨៩៤ ) *បូដឺលែរ* ( Baudelaire ១៨២០-១៨៦៧ ) *វែរឡែន* (Verlaine ១៨៤៤-១៨៩៦ ) ។ល។

## សំណួរ

១. វិទ្យាសាស្ត្រជាមូលដ្ឋាននៃអរិយធម៌បច្ចុប្បន្ន ៗ អ្នកយល់ដូចម្ដេច ?

២. រៀបរាប់អំពីចលនាទស្សនវិជ្ជាសំខាន់ៗ ៗ

៣. លទ្ធិសេដ្ឋកិច្ចសំខាន់ៗមានអ្វីខ្លះ? ប្លែកគ្នាត្រង់ណា ?

៤. ប្រលោមនិយមនិងប្រាកដនិយមប្លែកគ្នាដែរឬទេ ? រាប់ឈ្មោះកវីនិពន្ធល្បីល្បាញខាងប្រលោមនិយមនិងខាងប្រាកដនិយម ៗ

# ៣. ចក្រភពអាឡឺម៉ង់ ពីឆ្នាំ ១៨៧១ ដល់ឆ្នាំ ១៩១៤

តាំងពីឆ្នាំ ១៨៧១ ប្រទេសអាឡឺម៉ង់ជាមហាអំណាចទីមួយខាងយោធាក្នុងពិភពលោករួចទៅហើយ ។ នៅឆ្នាំ ១៩១៤ ប្រទេសអាឡឺម៉ង់ជាមហាអំណាចទីពីរខាងសេដ្ឋកិច្ចនិងនាវា ។ ម្យ៉ាងទៀត ប្រទេសអាឡឺម៉ង់មានប្រជាជនយ៉ាងច្រើន មានទ្រព្យសម្បត្តិយ៉ាងស្តុកស្តម្ភ មានវប្បធម៌យ៉ាងខ្ពង់ខ្ពស់ ។ ហេតុទាំងអស់នេះធ្វើឲ្យប្រទេសអាឡឺម៉ង់មានគំនិតលោភលន់យ៉ាងខ្លាំង ។

## ១. ស្ថាប័ននៃចក្រភពអាឡឺម៉ង់

ចក្រភពអាឡឺម៉ង់បានត្រូវប្រកាសឡើងនៅក្រុងវែរសៃ (Versailles) នៅថ្ងៃ ១៨ មករា ១៨៧១ ។ ចក្រភពនេះជាសហព័ន្ធមួយដែលមានរដ្ឋអធិបតេយ្យចំនួន ២៥ ជាសមាជិក ។ រដ្ឋសមាជិកទាំងអស់សុទ្ធតែមានរដ្ឋធម្មនុញ្ញ និងច្បាប់របស់គេផ្ទាល់ ។ មានតែកិច្ចការដែលទាក់ទងនឹងប្រយោជន៍រួមទេ ដែលជាបន្ទុករបស់រដ្ឋាភិបាលកណ្តាលនៃចក្រភព ។ ព្រះចៅអធិរាជជាប្រមុខនៃរដ្ឋាភិបាលដែលកាន់អំណាចនីតិប្រតិបត្តិ ។ អធិការបតីមួយរូប តែងតាំងឡើងដោយព្រះចៅអធិរាជ ជាអ្នកទទួលខុសត្រូវខាងនយោបាយរដ្ឋ ។ អំណាចនីតិបញ្ញត្តិត្រូវកាន់កាប់ដោយសភាពីរគឺ

— *សភាប៊ុនដេសរ៉ាត* ( Bundesrat ) ជាតំណាងរដ្ឋអាឡឺម៉ង់ ហើយដែលមានសមាជិកជាប្រតិភូនៃប្រមុខរដ្ឋនីមួយៗ

— *សភារ៉ៃតាក* ( Reichstag ) មានសមាជិកជាតំណាងរាស្ត្រ ជ្រើសតាំងដោយបោះឆ្នោតជាសកល ។

សភារ៉ៃតាកជាអ្នកអនុម័តច្បាប់ តែច្បាប់ទាំងនេះត្រូវតែទទួលការយល់ព្រមពីសភា

ប៊ុនដេសរ៉ាតដែរ ។ សភារ៉ៃតាកអនុម័តថវិកា ប៉ុន្តែពន្ធពីដើមមកនៅតែមានបន្តទៅទៀត ។ សភានេះមានអំណាចធ្វើសំណួរដេញដោលចំពោះអធិការបតី តែមិនអាចបញ្ឈប់អធិការបតីពីមុខតំណែងបានឡើយ ពីព្រោះអធិការបតីត្រូវទទួលខុសត្រូវចំពោះព្រះចៅអធិរាជ ។ ប្រទេស *ព្រុស* (Prusse) មាននាទីសំខាន់ជាងគេក្នុងចក្រភពអាល្លឺម៉ង់ ។ ប្រទេសនេះមានតំណាងរាស្ត្រចំនួន ២៣៦ នាក់ក្នុងសភារ៉ៃតាក ក្នុងចំនួនសមាជិកទាំងអស់ ៣៩៧ នាក់ ។ នៅក្នុងសភាប៊ុនដេសរ៉ាត ប្រទេសនេះអាចធ្វើឲ្យរដ្ឋធម្មនុញ្ញគ្មានបំលាស់ប្តូរអ្វីសោះក៏បានដែរ ។ ម្យ៉ាងទៀត អធិការបតីសុទ្ធតែជាជនជាតិព្រុស ហើយព្រះចៅអធិរាជអាល្លឺម៉ង់ក៏ជាព្រះរាជានៃប្រទេសព្រុសដែរ ។

## ២. ជនជាតិដែលចុះចូល

ជនជាតិដែលក្លាយខ្លួនទៅជាជនជាតិអាល្លឺម៉ង់ដោយការបង្ខិតបង្ខំ គឺជនជាតិដាណឺម៉ាកដែលមានចំនួនតិចល្មម ជនជាតិប៉ូឡូញ និងជនជាតិអាល់សាស-ឡូរ៉ែន ។



*លោកប៊ីស្មាក់ (១៨១៥-១៨៩៨)*

ពួកជនប៉ូឡូញរស់នៅក្នុងតំបន់ខាងកើតប្រទេសព្រុស ហើយមានគ្នាចំនួនប្រហែល ៣ លាននាក់ ។ រដ្ឋាភិបាលព្រុសបានសាកល្បងធ្វើឲ្យពួកជនប៉ូឡូញទាំងនេះយកសញ្ជាតិអាល្លឺម៉ង់ តែមិនសូវបានទទួលលទ្ធផលល្អប៉ុន្មានទេ ។

នៅឆ្នាំ ១៨៧១ អធិការបតី *ប៊ីស្មាក់* (Bismarck) បានយកខេត្តអាល់សាស-ឡូរ៉ែន ដាក់ទៅជាកម្មសិទ្ធិរួមរបស់រដ្ឋអាល្លឺម៉ង់ទាំងអស់ ដោយត្រូវទទួលការគ្រប់គ្រងផ្ទាល់ពីអធិការបតី ។ ក្រោយមក ខេត្តអាល់សាស-ឡូរ៉ែនក៏ត្រូវប្រែទៅជារដ្ឋអធិបតេយ្យ ដែលជាសមាជិកក្នុងសហព័ន្ធដូចរដ្ឋដទៃទៀតដែរ ។

## ៣. រដ្ឋាភិបាលប៊ីស្មាក់ ( ១៨៧១ - ១៨៩០ )

នៅក្នុងសភារ៉ៃតាក មានគណបក្សសំខាន់បីគឺ

— បក្សអភិរក្សនិយមដែលមានសមាជិកជាក្រុមម្ចាស់ដីធំៗ ចូលចិត្តរបបពាណិជ្ជកម្មឧបត្ថម្ភនិយម

— បក្សជាតិសេរីដែលមានសមាជិកជាឧស្សាហករ ពាណិជ្ជករ ចូលចិត្តរបបប្តូរដោយសេរីនិងរបបនយោបាយសេរី

— បក្សកាតូលិច ។

ពីឆ្នាំ ១៨៧១ ដល់ឆ្នាំ ១៨៧៨ ប៊ីស្មាក់បានពឹងផ្អែកលើបក្សជាតិសេរី ដើម្បីប្រឆាំងនឹងបក្សកាតូលិច ។ ក្រោយឆ្នាំ ១៨៧៨ ប៊ីស្មាក់បានចូលរួមជាមួយនឹងបក្សអភិរក្សនិយមនិងបក្សកាតូលិចប្រឆាំងនឹងពួកសង្គមនិយម ។

ប៊ីស្មាក់ពុំទុកចិត្តបក្សកាតូលិចឡើយ ។ គឺនៅក្នុងបក្សកាតូលិចនេះហើយ ដែលឃើញមានបក្សពួករបស់ប្រទេសអូទ្រីស បក្សពួករបស់ជនប៉ូឡូញ និងជនអាល់សាស - ឡូរ៉ែន ។ ម្យ៉ាងទៀត បុព្វសិទ្ធិរបស់គណៈសង្ឃកាតូលិចក្នុងប្រទេសព្រុស្សមានច្រើនណាស់ : គណៈសង្ឃកាតូលិចនេះស្ទើរតែគេចផុតនៅក្រោមអំណាចត្រួតត្រារបស់រដ្ឋាភិបាលសោះ ហើយម្យ៉ាងទៀត គណៈសង្ឃនេះបានកាន់បញ្ជីអត្រានុកូលដ្ឋាន និងគ្រប់គ្រងបឋមសិក្សាផង ។

នៅឆ្នាំ ១៨៧១ សភារ៉ៃតាកបានអនុម័តច្បាប់ជាវិធានការប្រឆាំងនឹងគណៈសង្ឃកាតូលិច ។ អធិបតេយ្យនៃរដ្ឋក៏ត្រូវប្រកាសឡើង អាពាហ៍ពិពាហ៍ស៊ីវិលក៏ត្រូវដាក់ឲ្យអនុវត្តជាទូទៅ ( កាលពីមុន គេរៀបអាពាហ៍ពិពាហ៍តែតាមផ្លូវសាសនា ) ។ សភាប្រទេសព្រុស្សបានប្រកាសបិទវិហារកាតូលិចជាច្រើន ព្រមទាំងដកសិទ្ធិគ្រប់គ្រងបឋមសិក្សាពីគណៈសង្ឃកាតូលិចទៀត ។ មន្ត្រីសង្ឃទាំងឡាយត្រូវតែងតាំងឡើងដោយរដ្ឋាភិបាល ។ តែក្រោយពីសម្តេចប៉ាប *ពីទី ៩* (Pie IX) សោយទិវង្គតទៅ ( ១៨៧៨ ) ប៊ីស្មាក់ក៏ចូលទៅចរចាជាមួយនឹងសម្តេចប៉ាបថ្មីព្រះនាម *លេអុង ទី ១៣* (LéonXIII) ។ ក្រោយមកគណបក្សកាតូលិចក៏ក្លាយទៅជាគណបក្សរបស់រដ្ឋាភិបាល ។

ក្នុងឱកាសដែលបីស្នាក់កាន់តែខិតចូលជិតគណបក្សកាតូលិច បីស្នាក់ក៏កាន់តែឃ្លាតឆ្ងាយពីគណបក្សជាតិសេរីដែរ ។ ដើម្បីទ្រទ្រង់កសិកម្មនិងឧស្សាហកម្ម បីស្នាក់ក៏ប្រកាន់យកនយោបាយពាណិជ្ជកម្មឧបត្ថម្ភនិយម ។ ក្នុងឱកាសនោះ បីស្នាក់ក៏ត្រូវប្រឆាំងនឹងពួកសង្គមនិយមដែរ ។ ពួកនេះបានបង្កើតគណបក្សមួយដែលមានកំលាំងមាំមួន ហើយដែលចេះតែមានការលូតលាស់ទៅមុខជានិច្ច ។ បីស្នាក់បានបំបាត់សមាគមនិងសារពត៌មានរបស់ពួកសង្គមនិយម ។ ប៉ុន្តែ បីស្នាក់ក៏បានសាកល្បងដោះស្រាយបញ្ហារបស់កម្មករដែរ ដើម្បីនាំឲ្យកម្មករចុះចូលទៅខាងរដ្ឋាភិបាល ។ ក្នុងករណីនេះ គេបានបង្កើតច្បាប់ធានារ៉ាប់រងអំពីជំងឺ គ្រោះថ្នាក់ និងជរាភាព ។ ទោះបីមានវិធានការយ៉ាងនេះក៏ដោយ គណបក្សសង្គមនិយមនៅតែរីកចំរើនតទៅទៀត ។

## ៤. ការរីកចំរើនខាងសេដ្ឋកិច្ចរបស់ប្រទេសអាឡឺម៉ង់

សារៈសំខាន់នៃប្រវត្តិរបស់ប្រទេសអាឡឺម៉ង់ចាប់ពីឆ្នាំ១៨៨៨មក មិនឋិតនៅលើការប្រឆាំងគ្នាខាងនយោបាយឡើយ តែនៅក្នុងការរីកចំរើនយ៉ាងសំបើមខាងសេដ្ឋកិច្ច ។ តាំងពីកំណើតដើមមក ចក្រភពអាឡឺម៉ង់ជាមហាអំណាចទី ១ ខាងយោធា ហើយនៅឆ្នាំ ១៩១៤ ចក្រភពនេះជាមហាអំណាចមួយខាងសេដ្ឋកិច្ចថែមទៀត ។

ពីឆ្នាំ ១៨៩០ ដល់ឆ្នាំ ១៩១៤ ប្រជាជនបានកើនចំនួនពី ៤៨ លានទៅ ៦៧ លាននាក់ ។ រហូតដល់ឆ្នាំ ១៨៩៥ ចំនួនមនុស្សដែលចេញពីប្រទេសអាឡឺម៉ង់ទៅសហរដ្ឋអាមេរិច និងប្រទេសប្រេស៊ីល មានសន្ទុះខ្លាំងណាស់ តែក្រោយមក ការរីកចំរើនខាងឧស្សាហកម្មបានបើកឱកាសឲ្យជនអាឡឺម៉ង់អាចរកការធ្វើបាននៅក្នុងប្រទេសវិញ ។

រហូតដល់ឆ្នាំ ១៨៨០ ប្រទេសអាឡឺម៉ង់ជាប្រទេសកសិកម្មមួយ ។ នៅឆ្នាំ១៩១៤ ប្រទេសនេះបានក្លាយទៅជារដ្ឋឧស្សាហកម្មដ៏សំខាន់មួយ ជាមួយនឹងសហរដ្ឋអាមេរិច និងចក្រភពអង់គ្លេស ។ ប្រទេសអាឡឺម៉ង់ត្រូវគេចាត់ជាប្រទេសទី ៣ ខាងផលិតកម្មធ្យូងថ្ម ទី ២ ខាងឧស្សាហកម្មលោហៈ និងទី ១ ខាងឧស្សាហកម្មអគ្គិសនី ស្ករ និងគីមី ។ ការរីកចំរើនយ៉ាងអស្ចារ្យនេះបណ្តាលមកពីបុព្វហេតុច្រើនយ៉ាង គឺមកពីដីសំបូរទៅដោយធ្យូងថ្ម ជាងជំនាញយ៉ាងច្រើនធ្វើការយកថ្លៃថោក ជនអាឡឺម៉ង់ច្រើនមានទេពកោសល្យក្នុងកិច្ចការរៀបចំ ព្រមទាំងមកពីការរីកចំរើនដុះដាលខាងវិទ្យាសាស្ត្រ បច្ចេកទេស និង

ឧស្សាហកម្ម ។ ចំពោះផលិតកម្មដែលកាន់តែរីកចំរើនរាល់ថ្ងៃនេះ ប្រទេសអាឡឺម៉ង់ត្រូវការរកផ្សារដើម្បីលក់ទំនិញ ។ នៅក្នុងប្រទេស រដ្ឋាភិបាលបានចំណាយថវិការាប់កោដិ ដើម្បីធ្វើផ្លូវរទេះភ្លើងយ៉ាងច្រើន រៀបចំផ្លូវទឹកដោយមានជីកព្រែក ប្រឡាយ និងសង់កំពង់ផែយ៉ាងទំនើបៗ ។ នៅក្រៅប្រទេស នៅគ្រប់ផ្សារទាំងអស់ ជាពិសេសនៅតំបន់ឡឺវ៉ង់ (Levant) អាស៊ីខាងកើត អាមេរិចខាងត្បូង ឈ្មួញជាតិអាឡឺម៉ង់តែងមានប្រៀបជាងឈ្មួញជាតិបារាំងនិងអង់គ្លេស ។ ម្យ៉ាងទៀត ឈ្មួញជាតិអាឡឺម៉ង់ក៏ចូលទៅធ្វើជំនួញនៅប្រទេសបារាំង និងអង់គ្លេសថែមទៀត ។ នៅឆ្នាំ ១៩១៤ ចំណុះនាវាជំនួញអាឡឺម៉ង់មានទំងន់ ៦ ដងលើសចំណុះនាវាកាលពីឆ្នាំ ១៨៨៨ ។

## ៥. រាជ្យរបស់គីយ៉ូមទី ២ (Guillaume II)

ព្រះចៅអធិរាជគីយ៉ូមទី ១ សុគតទៅនៅឆ្នាំ ១៨៨៨ ហើយរាជបុត្រព្រះនាម *ហ្វ្រេដេរិចទី ៣* (Frédéric III) សោយរាជ្យត តែព្រះចៅអធិរាជអង្គនេះសុគត ៣ ខែក្រោយមក ហើយព្រះចៅអធិរាជ *គីយ៉ូមទី ២* ក៏សោយរាជ្យតមក ។

កាយវិការដំបូងសំខាន់របស់ព្រះចៅអធិរាជអង្គនេះ គឺបានបញ្ឈប់ប៊ីស្មាក់ពីមុខតំណែងៗ ព្រះចៅអធិរាជមិនអាចទ្រាំទ្របានចំពោះចរិត ដែលមិនព្រមទទួលការជំទាស់របស់លោកអធិការបតី ។ ម្យ៉ាងទៀត ព្រះចៅអធិរាជនិងលោកអធិការបតីពុំដែលមានយោបល់ស្របគ្នាឡើយ ចំពោះបញ្ហាធំៗខាងនយោបាយក្នុងនិងក្រៅប្រទេស ។

ការបញ្ឈប់ប៊ីស្មាក់ពីមុខតំណែងពុំបានធ្វើឲ្យមានបំលាស់ប្តូរអ្វីសំខាន់ឡើយ នៅក្នុងប្រទេស ។ អធិការបតីទាំងឡាយ (អធិការបតីសំខាន់ជាងគេគឺ *ប៊ុយឡូ* (Bulow ១៩០០-១៩០៩) បន្តការគ្រប់គ្រងរដ្ឋដោយផ្អែកទៅលើគណបក្សកាតូលិច និងលើគណបក្សអភិរក្សនិយមដដែល ។ ឯគណបក្សសង្គមនិយមក៏កាន់តែរីកចំរើនឡើង ។ នៅឆ្នាំ ១៩១៤ គណបក្សនេះមានសមាជិកច្រើនជាងគេនៅក្នុងសភារ៉ៃតាក តែគណបក្សនេះមិនសូវប្រឆាំងនឹងរដ្ឋាភិបាលប៉ុន្មានដែរ ។

ព្រះចៅអធិរាជគីយ៉ូមទី ២ ទ្រង់យល់ថា បញ្ហាធំដែលជាអាយុជីវិតរបស់ប្រទេស

អាឡឺម៉ង់គឺបញ្ហាវត្ថុធាតុដើមនិងផ្សារសំរាប់លក់ទំនិញ ។ មកដល់ឆ្នាំ ១៨៩០ ប្រទេសអាឡឺម៉ង់មានអាណានិគមខ្លះនៅក្នុងទ្វីបអាព្រិច ដូចជាតូកោ (Togo) កាមេរូន (Cameroun) អាព្រិចនិរតី និងអាព្រិចខាងត្បូង ។ ក្រៅពីនេះ ប្រទេសអាឡឺម៉ង់ក៏បាននៅត្រួតត្រាលើកោះខ្លះនៅមហាសមុទ្រប៉ាស៊ីភិច និងដីសម្បទាននៅកាវចូវ (Kiao-Tcheou) ក្នុងប្រទេសចិនទៀត ។ ប៉ុន្តែ ប្រទេសអាឡឺម៉ង់ច្រើនយកបានទឹដីដែលមានសភាពសេដ្ឋកិច្ចអន់ជាងទឹដីដែលប្រទេសបារាំង និងអង់គ្លេសបានត្រួតត្រា ។ ដូចនេះ ប្រទេសអាឡឺម៉ង់ក៏យកប្រទេសអាស៊ីតួក (Asie Turque) ដាក់ជារដ្ឋអាណាព្យាបាលរបស់ខ្លួនថែមទៀត ដោយបានសង់ផ្លូវរទេះភ្លើងភ្ជាប់ក្រុងកុងស្តង់ទីណូប (Constantinople) ទៅនឹងឈូងសមុទ្រពែរ្ស (Golfe Persique) ផង ។ ដើម្បីការពារផលប្រយោជន៍នយោបាយ និងសេដ្ឋកិច្ចរបស់ខ្លួន ប្រទេសអាឡឺម៉ង់ត្រូវតែខ្លាំងពូកែ ។ កងនាវាចំបាំងជាតិអាឡឺម៉ង់ដែលមានឋានៈលេខ ២ ក្នុងពិភពលោក ជាសមិទ្ធិកើតឡើងដោយស្នាព្រះហស្ថ ព្រះចៅអធិរាជ ដោយមានសហប្រតិបត្តិការពីលោក *តៀពិត* (Tirpitz) ដែលជារដ្ឋលេខាធិការខាងនាវាចរ ។ ការរីកចំរើននៃកងនាវាចំបាំងរបស់អាឡឺម៉ង់នេះបានធ្វើឲ្យប្រទេសអង់គ្លេសមានសេចក្តីបារម្ភខ្លាំង ហើយបានជំរុញប្រទេសនេះឲ្យកាន់តែជិតជិតប្រទេសបារាំងឡើងៗ

ក្នុងវិស័យវប្បធម៌ ប្រទេសអាឡឺម៉ង់ក៏នៅតែមានសារៈសំខាន់ខ្ពង់ខ្ពស់ដដែល ។ ប្រទេសអាឡឺម៉ង់មានកវីនិពន្ធយ៉ាងជំនាញៗ មានទស្សនវិទូយ៉ាងសំខាន់ៗ ដូចជា *នីត* (Nietzsche) មានសិល្បករភ្លេងយ៉ាងល្បីៗដូចជា *វ៉ាកន័រ* (Wagner) និង *ស្រ្តូវ* (Strauss) ដោយមានគំនិតអំពីអានុភាពដាក់ស្តែងរបស់ប្រទេសខ្លួនក្នុងវិស័យវប្បធម៌ សេដ្ឋកិច្ច និងយោធា ជនជាតិអាឡឺម៉ង់ខ្លះយល់ថា ប្រទេសខ្លួនអាចត្រួតពិភពលោកបាន ជាហេតុនាំឲ្យប្រជាជាតិដទៃមានសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង ។

## សំណួរ

១. អធិប្បាយអំពីអំណាចនិតិប្រតិបត្តិនៅក្នុងចក្រភពអាឡឺម៉ង់ ។

២. អធិប្បាយអំពីអំណាចនីតិបញ្ញត្តិ ។

៣. ហេតុអ្វីក៏ប្រទេសព្រុស្សមាននាទីសំខាន់ជាងគេក្នុងចក្រភពអាឡឺម៉ង់ ?

៤. តើអធិការបតីចាត់វិធានការយ៉ាងណាខ្លះ ចំពោះជនជាតិដែលរស់នៅក្នុងចក្រភពអាឡឺម៉ង់ ?

៥. នៅឆ្នាំ ១៨៧១ ហេតុអ្វីក៏សភារីស្តាកចាត់វិធានការប្រឆាំងនឹងគណៈសង្ឃកាតូលិច ? តើវិធានការទាំងនោះមានអ្វីខ្លះ ?

៦. ការរីកចំរើនយ៉ាងខ្លាំងខាងសេដ្ឋកិច្ចរបស់ចក្រភពអាឡឺម៉ង់បណ្តាលមកពីអ្វីខ្លះ ? តើការរីកចំរើនចោទជាបញ្ហាអ្វីខ្លះ ចំពោះរដ្ឋាភិបាលអាឡឺម៉ង់ ?

៧. អធិប្បាយអំពីអាណានិគមរបស់ចក្រភពអាឡឺម៉ង់ ។

៨. តើមូលហេតុអ្វីខ្លះដែលធ្វើឲ្យចក្រភពអាឡឺម៉ង់យល់ថា ខ្លួនអាចត្រួតពិភពលោកបាន ?

# ៤. ប្រទេសអង់គ្លេស ពីឆ្នាំ ១៨៦៥ ដល់ ១៩១៤

នៅមុនសង្គ្រាមលោកលើកទី ១ ប្រទេសអង់គ្លេសបានចំរើនជាច្រើនក្នុងវិស័យ :

— នយោបាយក្នុងប្រទេស ដោយបាននិយមលទ្ធិប្រជាធិបតេយ្យទូលំទូលាយ

— នយោបាយសេដ្ឋកិច្ច នយោបាយអនុវត្តរបបប្តូរដោយសេរី (libre-échange)

— នយោបាយអាណានិគម ដោយបានពង្រីកទឹកដីចក្រភពឲ្យបានទូលាយ ។

## ១. ការចំរើនខាងលទ្ធិប្រជាធិបតេយ្យ

### ក. កំណែទំរង់នយោបាយ

ប្រទេសអង់គ្លេសបានប្រកាន់យក *លទ្ធិរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ* (monarchie constitutionnelle) ជាយូរយារណាស់មកហើយ ពោលគឺមិនមែនរាជានិយមផ្តាច់ការ (monarchie absolue) ដូចនៅប្រទេសដទៃឡើយ ។

តែនៅសម័យនោះ លទ្ធិប្រជាធិបតេយ្យអង់គ្លេសមិនទាន់មានលក្ខណៈបរិសុទ្ធក្លាមៗដែរ ពីព្រោះ :

— នៅ *សភាឡុត* (Chambre des Lords) ក៏ដូចជានៅ *សភាខុំមូន* (Chambre des Communes) ដែរ ពុំមានតំណាងប្រជាពលរដ្ឋទូទៅពិតប្រាកដទេ មានតែតំណាងពួកអ្នកមាននិងពួកអភិជន

— របៀបបោះឆ្នោតរើសតំណាងរាស្ត្រពុំមានលក្ខណៈដូចគ្នា នៅគ្រប់មណ្ឌលទាំងអស់ក្នុងប្រទេសអង់គ្លេសទាំងមូលឡើយ

— គេពុំដែលបានរើរៀបចំមណ្ឌលបោះឆ្នោតឡើងវិញឡើយ ។ មណ្ឌលខ្លះដែលប្រជាជនបានចាកចេញស្ទើរតែអស់ទៅហើយ ក៏នៅមានតំណាងរាស្ត្រដដែល ហើយ

មានមណ្ឌលខ្លះទៀត ដែលពលរដ្ឋបានកើនចំនួនជាច្រើន នៅតែមិនទាន់មានតំណាងរាស្ត្រ

— នៅសម័យបោះឆ្នោតម្ដងៗ មានអំពើពុករលួយជាច្រើន ៗ រីឯកិច្ចការរដ្ឋបាលទូទៅនៅក្នុងប្រទេសអង់គ្លេសទៀត ក៏ធ្លាក់ទៅក្នុងកណ្ដាប់ដៃពួកអ្នកមាននិងពួកអភិជនដែរ ៗ

អាស្រ័យហេតុដូចមាននៅខាងលើនេះហើយ បានជាគេនាំគ្នាកែទំរង់នយោបាយ ៗ កំណែទំរង់សំខាន់ៗបានធ្វើជាបីលើក គឺនៅឆ្នាំ ១៨៣២ ម្ដង នៅឆ្នាំ ១៨៦៧ ម្ដង និងឆ្នាំ ១៨៨៤-១៨៨៥ ម្ដងទៀត ៗ កំណែទំរង់ទាំងអស់នេះបានញាំងប្រទេសអង់គ្លេសឲ្យស្គាល់ *លទ្ធិប្រជាធិបតេយ្យដ៏បរិសុទ្ធមួយ* ដែលប្រទេសដទៃទៀតក្នុងលោកតែងយកមកធ្វើជាគំរូ ៗ

## ១. លក្ខណៈនៃលទ្ធិប្រជាធិបតេយ្យអង់គ្លេស

បន្ទាប់ពីកំណែទំរង់នេះមក ប្រជាពលរដ្ឋអង់គ្លេសមានសិទ្ធិបោះឆ្នោតជាសកល (ដល់មកឆ្នាំ ១៩១៨ ទើបស្ត្រីអង់គ្លេសមានសិទ្ធិបោះឆ្នោតដូចបុរស) ៗ ចំណែកឯរបៀបបោះឆ្នោតវិញក៏មានឯកភាពនៅគ្រប់មណ្ឌលទាំងអស់ក្នុងប្រទេសទាំងមូល ៗ

លទ្ធិប្រជាធិបតេយ្យអង់គ្លេស មានទំនៀមទំលាប់ជាមូលដ្ឋាន ពោលគឺ ជនជាតិអង់គ្លេសនិយមប្រតិបត្តិការផ្សេងៗ មុននឹងតាក់តែងច្បាប់ ៗ លុះសង្កេតថា ទំលាប់នេះជាការប្រសើរហើយ គេក៏រៀបចំច្បាប់សំរួលទៅ ៗ

នៅប្រទេសអង់គ្លេស ព្រះមហាក្សត្រសោយរាជសម្បត្តិ តែព្រះអង្គមិនគ្រប់គ្រងប្រទេសឡើយ ( le Roi règne, mais ne gouverne pas ) បានសេចក្ដីថា ព្រះមហាក្សត្រនៃប្រទេសអង់គ្លេសមិនជ្រៀតជ្រែកក្នុងកិច្ចការរបស់រដ្ឋាភិបាលទេ ហើយមិនដែលជំទាស់នឹងសេចក្ដីសំរេចរបស់សភាឡើយ ៗ ទំលាប់នេះត្រូវបានយកមកអនុវត្តយ៉ាងពេញលេញបំផុត ចាប់តាំងពីរជ្ជកាលព្រះមហាក្សត្រិយានី *វិចតូរា* (Victoria) គឺតាំងពីឆ្នាំ ១៨៣៧ ៗ

លទ្ធិប្រជាធិបតេយ្យអង់គ្លេសបានឆ្លងដែនប្រទេសអង់គ្លេស ទៅកាន់ប្រទេសដទៃទៀត ក៏ប៉ុន្តែ អនុវត្តន៍លទ្ធិនេះនៅបណ្ដាប្រទេសដទៃទាំងឡាយទៀតពុំបានជោគជ័យ ដូចនៅប្រទេសអង់គ្លេសឡើយ ៗ នៅសម័យជាមួយគ្នានោះ នៅប្រទេសបារាំង គណៈរដ្ឋ

មន្ត្រីត្រូវចំណុះសភា ។ ចំណែកនៅប្រទេសអង់គ្លេសវិញ គណៈរដ្ឋមន្ត្រីមានសេរីភាពនិងអំណាចច្រើន ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ។ នៅប្រទេសអង់គ្លេស គេទំលាប់ប្រគល់តំណែងនាយករដ្ឋមន្ត្រីទៅឲ្យគណបក្សណាដែលឈ្នះឆ្នោត គឺគណបក្សណាដែលមានតំណាងរាស្ត្រភាគច្រើននៅរដ្ឋសភា ។



*លោក ក្លាត់ស្តូន (១៨០៩-១៨៩៨)*



*លោក ឌីស្រាអែលី (១៨០៤-១៨៨១)*

ម្យ៉ាងទៀត តាមទំលាប់អង់គ្លេស តំណាងរាស្ត្រម្នាក់ៗត្រូវមានសេចក្តីស្មោះត្រង់នឹងគណបក្សរបស់ខ្លួនជានិច្ច ក្នុងរវាងមួយអាណត្តិរដ្ឋសភា ។

ដូចនេះ នៅប្រទេសអង់គ្លេស មិនសូវមានវិបត្តិគណៈរដ្ឋមន្ត្រី ដូចនៅប្រទេសបារាំងឡើយ ។ នៅសម័យមុនសង្គ្រាមលោកលើកទី១ ប្រទេសអង់គ្លេសមានគណបក្សនយោបាយតែពីរ គឺ *គណបក្សអភិរក្សនិយម* ( Parti conservateur ) និង *គណបក្សសេរីភាព* (Parti libéral) ។ នាយករដ្ឋមន្ត្រីពីររូប ដែលមានកិត្តិនាមជាងគេនៅសម័យនោះ គឺលោក *ឌីស្រាអែលី* ( Disraeli ) មេដឹកនាំគណបក្សអភិរក្សនិយម និងលោក *ក្លាត់ស្តូន* ( Gladstone )មេដឹកនាំគណបក្សសេរីភាព ។ វរជនទាំងពីររូបនេះសុទ្ធតែជាអ្នកស្រឡាញ់និងការពារលទ្ធិប្រជាធិបតេយ្យ តែមានមតិខុសគ្នាក្នុងនយោបាយក្រៅប្រទេស :

— លោកឌីស្រាអែលីនិយមអនុវត្តនយោបាយអាណានិគម

— លោកក្លាត់ស្តូននិយមសន្តិភាព ។

គួរកត់សំគាល់ថា ដំណើររីកចំរើននៃលទ្ធិប្រជាធិបតេយ្យនៅប្រទេសអង់គ្លេសបានប្រព្រឹត្តទៅដោយសន្តិវិធី គឺដោយគ្មានការបង្ហូរឈាម បដិវត្តន៍ ឬរដ្ឋប្រហារឡើយ ។

## ២. ការចំរើនខាងសេដ្ឋកិច្ច

ចាប់តាំងពីដើមសតវត្សទី ១៩ ម៉្លេះ ប្រទេសអង់គ្លេសជាមហាអំណាចមួយសំខាន់ក្នុងលោកខាងវិស័យសេដ្ឋកិច្ច ។

សេដ្ឋកិច្ចអង់គ្លេសរឹតតែបានចំរើនយ៉ាងឆាប់រហ័សថែមទៀត ចាប់តាំងពីឆ្នាំ ១៨៤៦ ដោយប្រទេសអង់គ្លេសបានប្រកាន់យក *លទ្ធិសេដ្ឋកិច្ចប្តូរដោយសេរី* គឺការបើកសិទ្ធិឲ្យដឹកនាំទំនិញចេញចូលដោយសេរី ដោយពុំគិតវ៉ូឲ្យបង់ពន្ធទំនិញទាំងនោះ ឬក៏យកតែបន្តិចបន្តួច ។ លោក *រីឆែត កុបឌិន* ( Richard Cobden ) ដែលជាឧស្សាហករល្បីឈ្មោះមួយរូប ជាអ្នកបានផ្តើមគំនិតណែនាំប្រទេសអង់គ្លេសឲ្យអនុវត្តលទ្ធិសេដ្ឋកិច្ចនេះ ។ ដោយកសិកម្មអង់គ្លេសពុំអាចប្រណាំងប្រជែងជាមួយនឹងបរទេសបាន ពពួកកសិករអង់គ្លេសបានប្រឆាំងនឹងរបបសេដ្ឋកិច្ចនេះជាខ្លាំង តែពុំបានសំរេច ហើយចាប់ពីឆ្នាំ ១៨៤៦ មកប្រទេសអង់គ្លេសក៏ចាប់អនុវត្តរបបសេដ្ឋកិច្ចប្តូរដោយសេរី តាមការណែនាំរបស់លោក ។

របបសេដ្ឋកិច្ចនេះបានផ្តល់ចំពោះប្រទេសអង់គ្លេសនូវផលវិបាកដ៏ប្រសើរដូចតទៅ :

— ជីវភាពរបស់ប្រជាពលរដ្ឋទូទៅបានធូរទូលាយ ដោយគ្រឿងឧបភោគបរិភោគបានចុះថ្លៃថោកជាខ្លាំង

— ឧស្សាហកម្មអង់គ្លេសបានចំរើនជាខ្លាំង ដោយវត្ថុធាតុដើមបានចូលទៅក្នុងប្រទេសអង់គ្លេសបានយ៉ាងស្រួល

— ពាណិជ្ជកម្មក៏បានចំរើន ដោយមានផ្សារច្រើន ។

ប្រទេសជាច្រើនបានយកគំរាប់តាមប្រទេសអង់គ្លេស ។ ម៉្លោះហើយ លទ្ធិសេដ្ឋកិច្ចនេះបានផ្តល់ផលវិបាកអាក្រក់ខ្លះទៅលើប្រទេសអង់គ្លេសវិញដែរ ចាប់តាំងពីឆ្នាំ ១៨៧៥ ពីព្រោះ :

— ឧស្សាហកម្មអង់គ្លេសរស់ដោយសារវត្ថុធាតុដើមបរទេស

— កសិកម្មអង់គ្លេសបានជួបប្រទះនឹងការពិបាកកាន់តែខ្លាំងឡើងទៀត ដោយត្រូវប្រណាំងប្រជែងនឹងកសិកម្មបរទេស

— ពាណិជ្ជកម្មអង់គ្លេសក៏មានការពិបាកដែរ ដោយប្រទេសអង់គ្លេសត្រូវប្រណាំងប្រជែងជាមួយនឹងប្រទេសដទៃទៀត ដែលបានចំរើនលូតលាស់ដែរ ដូចជាសហរដ្ឋអាមេរិចនិងប្រទេសអាល្លឺម៉ង់ជាដើម ។

## ៣. ការចំរើនខាងនយោបាយអាណានិគម

ប្រទេសអង់គ្លេស ក៏ដូចជាមហាអំណាចដទៃទៀតនៅទ្វីបអឺរ៉ុបដែរ បានខំពង្រីងនយោបាយអាណានិគមរបស់ខ្លួន នៅមុនសង្គ្រាមលោកលើកទី ១ ដើម្បីឲ្យបានសំរេច *គោលដៅ៤យ៉ាង* ដ៏សំខាន់គឺ

— រកវត្ថុធាតុដើមសំរាប់ឧស្សាហកម្មអង់គ្លេស

— រកផ្សារសំរាប់ទំនិញអង់គ្លេស

— តាំងមូលដ្ឋានសឹកអង់គ្លេសនៅបរទេស

— ពង្រីកកិត្យានុភាពអង់គ្លេសលើវិស័យរាបអន្តរជាតិ ។

នយោបាយអាណានិគមអង់គ្លេសច្រើនតែមានជោគជ័យជាងប្រទេសដទៃទៀតផង ៗ នៅមុនសង្គ្រាមលោកលើកទី ១ ស្រុកចំណុះអង់គ្លេសមានដូចតទៅ :

*នៅទ្វីបអាស៊ី*

— ឥណ្ឌា ( Inde )

— ភូមា ( Birmanie )

— ម៉ាឡាយូ ( Malaisie )

— សិង្ហបុរី ( Singapour )

— ចិន ( ហុងកុង និងភូមិភាគខ្លះនៃប្រទេសចិន )

— ស៊ីប ( Chypre)

— អាដិន ( Aden )

— អាប់កានីស្ថាន ( Afghanistan )

*នៅទ្វីបអាមេរិច*

— កាណាដា ( Canada )

— គុយយ៉ាន ( Guyane )

*នៅទ្វីបអាហ្វ្រិច*

— អេស៊ីប (Egypte)

— នីសេរ្យ៉ា (Nigéria)

— អាហ្វ្រិចខាងកើត(Afrique Orientale)

— អាហ្វ្រិចខាងត្បូង (Afrique Australe)

*នៅទ្វីបអូសេអានី*

— សេឡង់ថ្មី (Nouvelle-Zélande)

— អូស្ត្រាលី (Australie)

*នៅទ្វីបអឺរ៉ុប*

— អៀរឡង់ (Irlande)

នៅឆ្នាំ ១៩១៤ ស្រុកចំណុះអង់គ្លេសមានទំហំ ១/៤ នៃផ្ទៃដីពិភពលោក ហើយមានប្រជាជន ១/៤ នៃប្រជាជនពិភពលោក ។

ចំណែកឯរបបគ្រប់គ្រងស្រុកចំណុះទាំងនោះវិញ គ្មានលំនាំដូចគ្នាទេ ។ នៅក្នុងប្រទេសខ្លះ ដូចជានៅឥណ្ឌាជាដើម មានជនជាតិអង់គ្លេសរស់នៅតិចតួច តែជនទាំងនោះមានអំណាចទូលំទូលាយណាស់ ។ នៅក្នុងប្រទេសខ្លះទៀត ដូចជានៅអូស្ត្រាលី ជនជាតិអង់គ្លេសមានភាគច្រើន រីឯអ្នកស្រុកអាយមានចំនួនស្ដួចស្ដើង ។

## ៤. វិបត្តិនៅប្រទេសអៀរឡង់

ប្រទេសអៀរឡង់ជាកោះមួយឋិតនៅជិតប្រទេសអង់គ្លេស ហើយបានធ្លាក់ទៅក្នុងឥទ្ធិពលនៃប្រទេសនេះជង់ទៀត ។ ជនជាតិអៀរឡង់បានបំផុសចលនាជាតិទាមទារឯករាជ្យពីចក្រភពអង់គ្លេស ជាហេតុនាំឲ្យមានវិបត្តិឥតឈប់ឈររហូតដល់ឆ្នាំ ១៩១៤ ។ ឯវិបត្តិទាំងនោះមានដូចតទៅ :

ក. វិបត្តិសាសនា

ជនជាតិអៀរឡង់មានសិទ្ធិបោះឆ្នោតរើសតំណាងរាស្ត្រ ។ ប៉ុន្តែ គេត្រូវបាត់បង់សិទ្ធិនេះទៅវិញ ដោយជនជាតិអៀរឡង់ភាគច្រើនជាអ្នកកាន់គ្រិស្តសាសនាខាងនិកាយកាតូលិច ។ ម្យ៉ាងទៀត ជនជាតិអៀរឡង់ទាំងនោះត្រូវបង់ពន្ធសាសនា (dîme) ឲ្យទៅវិហារខាងជាតិអង់គ្លេស ។

ដោយសារការតវ៉ាយ៉ាងម៉ឺងម៉ាត់របស់ជនជាតិអៀរឡង់ ដែលមានលោក *អូខូណែល* (O'Connell) ជាអ្នកដឹកនាំ រដ្ឋាភិបាលអង់គ្លេសបានសុខចិត្ត :

— នៅឆ្នាំ ១៨២៩ លុបច្បាប់បំបាត់សិទ្ធិបោះឆ្នោតចំពោះជនជាតិអៀរឡង់ណា ដែលកាន់គ្រិស្តសាសនាខាងនិកាយកាតូលិច ។

— នៅឆ្នាំ ១៨៥៩ លុបច្បាប់បង្ខំពួកកាតូលិចអៀរឡង់ឲ្យបង់ពន្ធសាសនាឲ្យវិហារអង់គ្លេស ។

ខ. បញ្ហាកសិកម្ម

ពីដើម ដីស្រែចំការទាំងអស់ជាដីកម្មសិទ្ធិរបស់ជនជាតិអៀរឡង់ ។ លុះដល់ប្រទេស

អៀឡង់ត្រូវឋិតនៅក្រោមអំណាចអង់គ្លេស ដីស្រែចំការភាគច្រើននៅអៀឡង់ ហើយជាពិសេស ដីណាដែលមានដីជាតិល្អ បានធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់ជនជាតិអង់គ្លេសដែលភាគច្រើន ច្រើនតែទុកដីទាំងនោះឲ្យនៅទំនេរសំរាប់ធ្វើជាកន្លែងបរបាញ់សត្វកំសាន្ត ជាហេតុនាំឲ្យមានទុរភិក្សជាញឹកញាប់នៅប្រទេសអៀឡង់ ដូចជាទុរភិក្សនៃឆ្នាំ ១៨៤៥ ជាដើមដែលបណ្ដាលឲ្យមនុស្សស្លាប់អស់ប្រហែល ៥០០ ០០០ នាក់ ។

ក្រោមការណែនាំនៃលោក *ប៉ាណែល* (Parnell) ជនជាតិអៀឡង់បានតវ៉ាសុំឲ្យជនជាតិអង់គ្លេសលែងដណ្ដើមយកដីស្រែចំការ ពីជនជាតិអៀឡង់តទៅទៀត ហើយបានសុំឲ្យជនជាតិអង់គ្លេសព្រមលក់ដីចំការទាំងនោះឲ្យទៅជនជាតិអៀឡង់វិញ ។ ដើម្បីឲ្យជនជាតិអៀឡង់មានលុយកាក់សំរាប់ទិញដីស្រែចំការទាំងនោះបាន រដ្ឋាភិបាលអង់គ្លេសបានអនុញ្ញាតជនជាតិអៀឡង់ឲ្យអាចខ្ចីប្រាក់បាន ។

តែការទាមទារទាំងនេះពុំសូវបានលទ្ធផលល្អទេ ដោយម្ចាស់កម្មសិទ្ធិជាតិអង់គ្លេសច្រើនពុំព្រមលះបង់ចោលបុព្វសិទ្ធិរបស់ខ្លួន ។

គ. បញ្ហានយោបាយ

បញ្ហានយោបាយទាក់ទងនឹងបញ្ហាសាសនា ។ ប្រទេសអៀឡង់មានរដ្ឋសភាដែរ តែមិនមានតំណាងជនជាតិអៀឡង់ពិតប្រាកដទេ ពីព្រោះជនជាតិអៀឡង់ភាគច្រើនបានបាត់បង់សិទ្ធិបោះឆ្នោតដោយសាររឿងសាសនា ។

ដោយសារការតវ៉ាឥតឈប់ឈរ និងការប្រយុទ្ធខាងផ្លូវសឹកយ៉ាងស្វិតស្វាញរបស់ជនជាតិអៀឡង់ លោកក្លាត់ស្តូនបានស្នើសភាអង់គ្លេសនៅឆ្នាំ ១៨៨៤ ឲ្យទទួលស្គាល់ *ស្វ័យភាព* (Home Rule) នៃប្រទេសអៀឡង់ តែមិនបានសំរេចដូចបំណងទេ ។ លុះមកដល់ឆ្នាំ ១៩១៤ ទើបប្រទេសអង់គ្លេសព្រមប្រគល់ស្វ័យភាពទៅឲ្យប្រទេសអៀឡង់ ។ ប៉ុន្តែ ស្វ័យភាពនោះមាននៅតែលើក្រដាសទេ ពីព្រោះរហូតមកដល់ឆ្នាំ ១៩២១ ទើបគេយកស្វ័យភាពនោះមកអនុវត្តឲ្យបានត្រឹមត្រូវពេញលេញ បន្ទាប់ពីមានការបង្ហូរឈាម ។

លើកលែងតែវិបត្តិនៃប្រទេស អៀឡង់ នេះចេញ ប្រទេសអង់គ្លេសបានចំរើនជាខ្លាំងគ្រប់វិស័យទាំងអស់ នៅមុនសង្គ្រាមលោកលើកទី ១ ។

# សំណួរ

១. បង្ហាញនិងពន្យល់វិវត្តន៍លទ្ធិប្រជាធិបតេយ្យអង់គ្លេស ។

២. បង្ហាញលក្ខណៈពិសេសនៃលទ្ធិប្រជាធិបតេយ្យអង់គ្លេស ។

៣. របបប្តូរដោយសេរីបានផ្តល់ផលវិបាកយ៉ាងណាខ្លះចំពោះសេដ្ឋកិច្ចអង់គ្លេស នៅសម័យមុនសង្គ្រាមលោកលើកទី ១ ?

៤. គូរផែនទីបង្ហាញស្រុកចំណុះអង់គ្លេសនៅឆ្នាំ ១៩១៤ ។

៥. វិបត្តិនៅប្រទេសអៀរឡង់បានចោទបញ្ហាអ្វីខ្លះ នៅសម័យមុនសង្គ្រាមលោកលើកទី ១ ? រៀបរាប់ពន្យល់បញ្ហាទាំងនោះ ហើយបង្ហាញដំណោះស្រាយផង ។


ស មុ ទ្រ ឧ ត្ត រ
ម ហា ស មុ ទ្រ
អា ត្លង់ ទិច
សមុទ្រ ម៉ង់
អេ
កុស
អង់
គ្លេស
អេប៊ីឌីន
ឌិនឌី
អេឌិមបួ
ហ៊ុល
ប្រីស្តុល
តំបន់ គាល
ផតស្មៅ
ប្រៃតុន

*ប្រជុំកោះអង់គ្លេស*

# ៥. ប្រទេសបារាំង
# ពីឆ្នាំ ១៨៧១ ដល់ ១៩១៤

ការចុះចាញ់នៃអធិរាជណាប៉ូលេអុងទី ៣ ចំពោះកងទ័ពអាល្លឺម៉ង់នៅក្រុងសឺដង់ (Sedan) ក្នុងថ្ងៃទី ១ កញ្ញា ១៨៧០ បណ្ដាលឲ្យផ្ទុះបដិវត្តន៍ថ្ងៃទី ៤ កញ្ញា ដែលរំលំរបបអធិរាជ ហើយដែលប្រកាសជាសាធារណរដ្ឋទី ៣ ឡើង ។ ប៉ុន្តែ របបគ្រប់គ្រងថ្មីនេះ មិនទាន់រឹងប៉ឹងនៅឡើយទេ ព្រោះនៅមានទាស់ទែងប្រឆាំងគ្នារវាងអ្នកសាធារណរដ្ឋនិយមនិងពួករាជានិយម ។ លុះត្រាតែបានច្រើនឆ្នាំកន្លងមក ទើបជនជាតិបារាំងភាគច្រើនព្រមទទួលយករបបសាធារណរដ្ឋនេះ ។

## ១. កំណើតសាធារណរដ្ឋទី ៣

### ក. រដ្ឋាភិបាលការពារជាតិ

ក្រោយបរាជ័យនៅ*ក្រុងសឺដង់* របបអធិរាជនៃព្រះចៅ *ណាប៉ូលេអុងទី ៣* មិនអាចរស់រានបានទៀតឡើយ ។ នៅថ្ងៃទី ៤ កញ្ញា ១៨៧០ មហាជនក្រុងប៉ារីបានទំលាក់អធិរាជអង្គនេះ ដើម្បីប្រកាសប្រទេសបារាំងជា *សាធារណរដ្ឋ* ហើយបង្កើតរដ្ឋាភិបាលបណ្ដោះអាសន្នមួយ ដោយឥតបង្ហូរឈាមមួយតំណក់សោះឡើយ ។ សមាជិករដ្ឋាភិបាល ដូចជាលោក *កំបែតា* (Gambetta) លោក *ស៊ុល ផាវ* (Jules Favre) លោក *ស៊ុល ភែរី* (Jules Ferry) ដែលជាតំណាងរាស្ត្រនិយមសាធារណរដ្ឋនោះ បានដាក់ឈ្មោះរដ្ឋាភិបាលបណ្ដោះអាសន្ននោះថា រដ្ឋាភិបាលការពារជាតិ ។

ក្រោយពីបានទិតំទិតស៊ូអស់រយៈពេលបួនប្រាំខែមក រដ្ឋាភិបាលការពារជាតិដែលពុំអាចទប់ទល់នឹងកំលាំងទ័ពអាល្លឺម៉ង់តទៅទៀតបាន ក៏សំរេចសុំផ្អាកសង្គ្រាមនៅថ្ងៃទី ២៨ មករា ១៨៧១ ។ បន្ទាប់ពីបានបោះឆ្នោតរើសសមាជិករដ្ឋសភាជាតិរួចហើយ ប្រទេសបារាំងក៏បានចុះ *សន្ធិសញ្ញាសន្តិភាព* ជាមួយនឹងប្រទេសអាល្លឺម៉ង់នៅក្រុង *ប្រង់ផរ* (Francfort)

ក្នុងខែឧសភា ១៨៧១ (១) ។

### ខ. រដ្ឋាភិបាលលោកធែ (Thiers) (១៨៧១-១៨៧៣)



លោកធែ

តំណាងរាស្ត្រដែលជាប់ឆ្នោតនៅថ្ងៃទី ៨ កុម្ភៈ ១៨៧១ ច្រើនតែជាអ្នកនិយមរាជាធិបតេយ្យ ។ ក្នុងសម័យប្រជុំពេញអង្គនៅក្រុងបរដូ (Bordeaux) រដ្ឋសភាបានចាត់តាំងលោក *ធែ* ឲ្យធ្វើជានាយករដ្ឋាភិបាល ដោយបានទាំងប្រគល់អំណាចយ៉ាងពេញបរិបូណ៌ដល់លោកទៀតផង ។ នៅឱកាសនោះ(មីនា ១៨៧១) អ្នកបដិវត្តវណ្ណៈពលករនៅក្រុងប៉ារី បានរួបរួមគ្នាបង្កបង្កើតជាអង្គការបដិវត្តមួយហៅថា « សហព័ន្ធសាធារណរដ្ឋនៃទ័ពជាតិ» (Fédération républicaine de la garde naticnale) ដឹកនាំដោយគណៈកម្មាធិការកណ្ដាល ។

លោកធែនិងរដ្ឋសភាជាតិក៏បានសំរេចថា ត្រូវតែកំចាយគណៈកម្មាធិការបដិវត្តន៍នេះចោល ។ ចំបាំងស៊ីវិលក៏កើតក្លាម ហើយដែលគេឲ្យឈ្មោះថា *«កុំមូនក្រុងប៉ារី»* (Commune de Paris) ។ ចំបាំងនេះមានថេរវេលាខ្លីទេ គឺពីថ្ងៃទី ២១ ដល់ ២៨

*(១) សន្ធិសញ្ញាសន្តិភាពក្រុងប្រង់ផរ តំរូវប្រទេសបារាំងឲ្យប្រគល់ខេត្តអាល់សាសនិងឡូវ៉ែនមួយភាគទៅប្រទេសអាឡឺម៉ង់ និងបង់ប្រាក់បំណាច់ចំនួន ៥ ០០០ លានប្រង់បាសឲ្យបានមុនខែមីនា ១៨៧៥ ។*

ឧសភា ១៨៧១ តែមានការកាប់សំលាប់គ្នាសំបើមគួរឱ្យរន្ធត់បំផុត ដែលហៅថា *«អាទិត្យបង្ហូរឈាម»* (Semaine sanglante) ។ អគ្គិការបដិវត្តនៃវណ្ណៈពលករដែលពុំទាន់មានឯកភាពនៅឡើយនោះក៏ត្រូវវិនាសខ្ទាត់ខ្ទាយទៅ ក្រោមការបង្ក្រាបយ៉ាងឃោរឃៅសំបើមរបស់អ្នកកាន់អំណាចមូលធននិយម ។



*អគ្គិភ័យនៅសណ្ឋាគារក្រុង (ក្រុមអ្នកបដិវត្តន៍ចុងក្រោយនៅអំឡុងអាទិត្យបង្ហូរឈាម)*

នៅពេលនោះ គេសង្កេតឃើញថា ពួកអ្នកសាធារណរដ្ឋនិយមបានព្រមព្រៀងផ្អាកទំនាស់តទៅទៀត ដើម្បីរួមគ្នារកផ្លូវសាងប្រទេសជាតិជាថ្មី និងរំដោះដែនដីអាល់សាស-ឡូរ៉ែនពីអាឡឺម៉ង់មកវិញ ។

នៅក្នុងខែសីហា ១៨៧១ រដ្ឋសភាបានតែងតាំងលោកធៀជាប្រធានាធិបតីនៃសាធារណរដ្ឋបារាំង ដោយទុកនាទីឱ្យលោកទទួលខុសត្រូវខាងរដ្ឋាភិបាលទៀតផង ។

ក្រោមការចាត់ចែងរបស់លោកធៀ ហិរញ្ញវត្ថុប្រទេសបារាំងក៏មានស្ថានភាពល្អឡើងវិញ ។ កងទ័ពទៀតសោតក៏ត្រូវបានរៀបចំឱ្យទំនើបឡើងដែរ ។

បន្ទាប់មក បញ្ហារបបគ្រប់គ្រងក៏ពានចោទឡើង ។ លុះដឹងថា លោកធៀទុកប្រទេសបារាំងឱ្យនៅជាសាធារណរដ្ឋ ពួកអ្នករាជានិយមក៏រកល្បិចបង្ខំលោកឱ្យលាលែងពីមុខតំណែងទាល់តែបាន នៅខែឧសភា ១៨៧៣ ហើយក៏តែងតាំងលោកសេនាប្រមុខ

*ម៉ាក់ម៉ាហុង* (Mac-Mahon) ជំនួសលោកវិញ ។

### គ. «សាធារណរដ្ឋ» លោកម៉ាក់ម៉ាហុង (១៨៧៣-១៨៧៩)

លោក *ម៉ាក់ម៉ាហុង* ជានាយទាហានរាជានិយម និងជាអ្នកការពារសាសនាកាតូលិច ។ ក្រោយដែលបានឡើងជាប្រធានាធិបតីហើយ លោកក៏ប្រគល់អំណាចរដ្ឋាភិបាលទៅ *ឌុចដឺប្រូយ* (duc de Broglie) ដើម្បីឲ្យរៀបចំកំចាត់គំនិតសាធារណរដ្ឋឲ្យអស់ ។ ដើម្បីចាត់ចែងគំរោងការនេះឲ្យបានជោគជ័យ គេបានរៀបចំនីតិកាលប្រធានាធិបតី ម៉ាក់ម៉ាហុង រហូតដល់ទៅ ៧ ឆ្នាំ ។

ក៏ប៉ុន្តែ ការសាកល្បងស្ដាបនារបបរាជាធិបតេយ្យឡើងវិញនោះពុំបានសំរេចឡើយ ។

អស់សង្ឃឹម អ្នករាជានិយមក្នុងរដ្ឋសភាក៏ព្រមអនុម័តរដ្ឋធម្មនុញ្ញ (១៨៧៥) ដែលស្ដាបនាប្រទេសបារាំងជាសាធារណរដ្ឋ ។

សម័យបោះឆ្នោតឆ្នាំ ១៨៧៦ បានឲ្យសំលេងភាគច្រើនលើសលុបក្នុងរដ្ឋសភា ទៅអ្នកសាធារណរដ្ឋនិយម ។

ដើម្បីឲ្យស្របទៅតាមច្បាប់ លោកម៉ាក់ម៉ាហុងក៏ព្រមឲ្យបង្កើតគណៈរដ្ឋមន្ត្រីសាធារណរដ្ឋនិយមដែលមានលោក *ស៊ុល ស៊ីម៉ុង* (Jules Simon) ជានាយក ។ ប៉ុន្តែ ប៉ុន្មានខែក្រោយមក លោក *ម៉ាក់ ម៉ាហុង* បានរំលាយគណៈរដ្ឋមន្ត្រីនេះចោល ហើយប្រគល់អំណាចរដ្ឋាភិបាលទៅ *ឌុច ដឺប្រូយ* ម្ដងទៀត ។ ទំនាស់ខ្លាំងក្លារវាងលោកម៉ាក់ម៉ាហុងនិងរដ្ឋសភាដែលភាគច្រើនជាអ្នកនិយមសាធារណរដ្ឋនោះ ក៏ចាប់កំណើតឡើង ។ លុះដល់មកឆ្នាំ ១៨៧៩ អ្នកសាធារណរដ្ឋនិយមឈ្នះឆ្នោតក្នុងព្រឹទ្ធសភាទៀត លោកម៉ាក់ម៉ាហុងត្រូវតែបង្ខំចិត្តលាលែងពីតំណែងប្រធានាធិបតីនៅពេលនោះដែរ ។ លោក ស៊ុលគ្រេវី (Jules Grévy) ដែលជាអ្នកសាធារណរដ្ឋនិយម បានឡើងកាន់ការជំនួសវិញ ។

## ២. ដំណើរវិវត្តន៍នៃសាធារណរដ្ឋទី ៣ (១៨៧៩-១៩១៤)

បន្ទាប់ពីបានទទួលជោគជ័យលើពួករាជានិយមមក អ្នកនិយមរបបសាធារណរដ្ឋបាក់បែកគ្នាជាពីរក្រុម ទៅតាមទំនោរនយោបាយរៀងខ្លួន គឺក្រុមរ៉ាឌីកាល់ (radical) និងក្រុមកាលនិយម (opportuniste) ។

ក្រុមរ៉ាឌីកាល់ ដែលមានលោក *ក្លីម៉ង់សូ* (Clemenceau) ជាអ្នកដឹកនាំ មានបំណងធ្វើឲ្យកម្មវិធីសាធារណរដ្ឋសំរេចបាន ទាំងស្រុងហើយជាបន្ទាន់ផង ។ រីឯពួកកាលនិយមដែលមានលោក *កំបែតា* (Gambetta) និងលោក *ស៊ុលភែរី* (Jules Ferry) ជាមេវិញនោះ ប្រាថ្នាសំរេចកម្មវិធីមួយផ្នែកម្ដងៗ ដោយសន្សឹមៗទៅតាមឱកាសដែលហុចឲ្យ ។



*លោកក្លីម៉ង់សូ*

### ក. សាធារណរដ្ឋកាលនិយម (១៨៧៩-១៨៨៥)

ដោយក្រុមកាលនិយមមានគ្នាច្រើន នយោបាយសាធារណរដ្ឋបារាំងជំនាន់នោះក៏ត្រូវបាននយោលទៅតាមកម្មវិធីនៃក្រុមនេះដែរ ។

កិច្ចការកែទំរង់ផ្សេងៗក៏ត្រូវបានរៀបចំធ្វើឡើងជាបន្តបន្ទាប់ :

— សំរាល ឬលើកលែងចោលនូវទោសនយោបាយ

— បំបាត់លក្ខណៈសាសនាក្នុងសិក្សាធិការ

— បើកឲ្យរៀនសូត្រដោយឥតបង់ថ្លៃនិងដោយបង្ខំនៅបឋមសិក្សា

— បើកសេរីភាពក្នុងការប្រជុំសេរីភាពសារពត៌មាន

— អនុញ្ញាតឲ្យបង្កើតសហជីព (syndicat) វិជ្ជាជីវៈ ។

លុះដល់មកឆ្នាំ ១៨៨៥ ក្រោយដែលគណៈរដ្ឋមន្ត្រីលោកស៊ុលភែរីរលំទៅ(១) ប្រទេស

*(១) បន្ទាប់ពីបានដំណឹងបរាជ័យនៃទ័ពអាណានិគមបារាំង នៅឡាងសឺង (Lang Son) (មីនា ១៨៨៥) ក្នុងស្រុកយួនតុងកឹងបកមតិមហាជនបារាំងក៏រិះគន់នយោបាយអាណានិគមរបស់លោកស៊ុល ភែរី ជាខ្លាំង បណ្ដាលឲ្យលោកលាឈប់ពីតំណែងនាយករដ្ឋមន្ត្រីនៅពេលនោះតែម្ដង ។*

បារាំងក៏បានប្រទះនឹងវិបត្តិយ៉ាងធ្ងន់ ជាហេតុនាំឱ្យមានការមិនសប្បាយចិត្តខ្លះក្នុងមជ្ឈដ្ឋានមហាជន ។ ក្រុមអ្នកប្រឆាំងនឹងនយោបាយសាធារណរដ្ឋនិយមសភាបានធ្វៀតឱកាសនេះប៉ុនប៉ងរំលាយរំលំរបបនេះចោល ។



*លោកស៊ុលហ្វេរី*

## ១. ជ័យជំនះនៃរបបសាធារណរដ្ឋ

ដើម្បីរំលាយរបបថ្មីនេះ ក្រុមអ្នកប្រឆាំងក៏បាននាំគ្នាពឹងផ្អែកលើលោក *ប៊ូឡង់សេ* (Boulanger) ដែលជាឧត្តមសេនីយប្រជាប្រិយមួយរូបនៅសម័យនោះ ។

បន្ទាប់ពីត្រូវបណ្តេញចេញពីគណៈរដ្ឋមន្ត្រី (ឧសភា ១៨៨៧) និងត្រូវដាក់ឱ្យចូលនិវត្តន៍មក (មីនា ១៨៨៨) លោកប៊ូឡង់សេក៏បានបង្កើត*គណបក្សសេរីនិយម*មួយ ប្រាថ្នារំលាយអង្គការសភាចោលនិងរៀបចំធ្វើរដ្ឋធម្មនុញ្ញជាថ្មីដែលផ្តល់អំណាចពេញលេញមកឱ្យលោក ។ ការបោះឆ្នោតបំពេញកន្លែងក្នុងរដ្ឋសភាបានបញ្ជាក់ឱ្យដឹងថា លោកប៊ូឡង់សេមានប្រជាប្រិយភាពខ្លាំងក្លាណាស់*(១)* ។ ឃើញដូចនេះ ក្រុមប៊ូឡង់សេនិយមដែលភាគច្រើនជាអ្នករាជានិយមនោះ បានសង្ឃាតនាំលោកប៊ូឡង់សេឱ្យធ្វើរដ្ឋប្រហារ តែលោកពុំហ៊ានសោះ ។

ឈមមុខនឹងស្ថានការណ៍ដ៏មានគ្រោះថ្នាក់នេះ អ្នកសាធារណរដ្ឋនិយមគ្រប់និន្នាការទាំងអស់បានរួបរួមកំលាំងគ្នាតទល់នឹងក្រុមប៊ូឡង់សេនិយម ដើម្បីរក្សាការពាររបបសាធារណរដ្ឋឱ្យរស់រានតទៅមុខ ។ ក្នុងគំនិតនេះ គេក៏បានសំរេចធ្វើច្បាប់លែងអនុញ្ញាតឱ្យជន

---

*(១) ពីដើម តំណាងរាស្ត្រម្នាក់អាចឈរឈ្មោះនៅច្រើនមណ្ឌលបាន ។ ដូចនេះហើយ បានជាក្នុងរយៈកាលតែប្រាំខែ លោកប៊ូឡង់សេម្នាក់ឯងបានជាប់ឆ្នោតជាតំណាងរាស្ត្រក្នុងប្រាំមួយមណ្ឌល ដើម្បីជួសបំពេញកន្លែងដែលខ្វះក្នុងសភាជាតិ ។*

ម្នាក់អាចធ្វើជាតំណាងរាស្ត្រនៅច្រើនមណ្ឌលបានទៀត ។ ម្យ៉ាងទៀត គេខំប្រមូលលេសគ្រប់យ៉ាងដើម្បីចោទលោកប៊ូឡង់សេក្នុងបទបង្កការជ្រួលច្របល់ក្នុងរដ្ឋ ។

ភ័យខ្លួន លោកប៊ូឡង់សេក៏បានរត់ទៅនៅក្រុងប្រ៊ុចសែល (Bruxelles) ក្នុងប្រទេសបែលស៊ិចបាត់ទៅ (មេសា ១៨៨៩) ។ ចាប់ពីពេលនោះមក ប្រជាប្រិយភាពរបស់លោកក៏ធ្លាក់ចុះយ៉ាងខ្លាំង ហើយគណបក្សប៊ូឡង់សេនិយមក៏ត្រូវបរាជ័យយ៉ាងធ្ងន់ក្នុងសម័យបោះឆ្នោតខែកញ្ញា ឆ្នាំ១៨៨៩ *(១)* ។ លទ្ធិប៊ូឡង់សេនិយមក៏រលាយទៅ បរិយាកាសស្ងប់ស្ងាត់ក៏កើតមានឡើងវិញ ។ តែគួរកត់សំគាល់ថា ចាប់តាំងពីពេលនោះមក ទស្សនៈរាជានិយមក៏លែងមានកំលាំងជាអង្គការនយោបាយទៀត ។ ផ្ទុយទៅវិញ លទ្ធិសង្គមនិយមបានចាប់ផ្តើមចេញមុខជាកំលាំងនយោបាយក្នុងផ្ទៃសភា ។ ម្យ៉ាងទៀត ចលនាសហជីពក៏បានរីកលូតលាស់ណាស់ដែរ ។

### គ. វិវត្តន៍ទៅរកនិន្នាការខាងឆ្វេង

ក្រោយដែលបានសំចតនៅក្នុងនយោបាយសំរុះសំរួលអស់មួយរយៈពេលមក ប្រទេសបារាំងក៏បានផ្តើមអនុវត្តនយោបាយជឿនលឿនមួយកំរិតទៅមុខទៀត ។

* *បញ្ហាសាសនា.*— នៅឆ្នាំ ១៩០៥ សភាបារាំងបានអនុម័តច្បាប់មួយ ដើម្បីផ្តាច់វិស័យសាសនាចេញពីអង្គការរដ្ឋ ។ សាធារណរដ្ឋបារាំងត្រូវមានជំហរ ជាអព្យាក្រឹតក្នុងវិស័យសាសនា ពោលគឺបើកសេរីភាពពេញលេញខាងជំនឿជូនមហាជន ។

* *ជីវភាពនយោបាយ .*— ដោយគោរពតាមសេចក្តីសំរេចរបស់សមាជអន្តរជាតិនៃបក្សសង្គមនិយម ដែលរៀបចំឡើងនៅក្រុងអាំស្ទែដាំ (ប្រទេសពេអ៊ុបា) ក្នុងឆ្នាំ ១៩០៤ នោះ *(២)* អ្នកសង្គមនិយមបារាំងមួយភាគក៏បានដកខ្លួនចេញពីប្លុកសាធារណរដ្ឋ ហើយរួមគ្នាបង្កើតជាគណបក្សសង្គមនិយមមួយដែលមានឈ្មោះថា គណបក្សកម្មករអន្តរជាតិផ្នែកបារាំង (Section Française de l'Internationale Ouvrière : S. F. I. O.) ។

---

(១) *តំណាងរាស្ត្រនៃគណបក្សប៊ូឡង់សេនិយមជាប់ឆ្នោតបានតែ ៤៥ នាក់ទេ រីឯតំណាងរាស្ត្រសាធារណរដ្ឋនិយមវិញ មានដល់ទៅ ៣៦០ នាក់ ។*

(២) *សមាជអន្តរជាតិនៃបក្សសង្គមនិយម នៅក្រុងអាំស្ទែដាំ បានហាមប្រាមបក្សសង្គមនិយមគ្រប់ប្រទេសមិនឲ្យរួបរួម ឬសំរបសំរួលជាមួយនឹងបក្ស «មូលធននិយម» ក្នុងប្រទេសសោះឡើយ ។*

ឃើញដូចនេះ គណបក្សគ្រប់និន្នាការដទៃទៀតក៏បានប្រមូលគ្នា រួមជាកំលាំងមួយត ទប់នឹងគណបក្សថ្មីនេះ ។ បន្ទាប់ពីសម័យបោះឆ្នោតឆ្នាំ ១៩០៦ មក ក្រុមរ៉ាឌីកាល់ដែល មានលោកក្លឺម៉ង់សូជាមេ បានឡើងកាន់អំណាចរដ្ឋាភិបាលបរហូតដល់ឆ្នាំ ១៩០៩ ។ តែ លុះដល់គណៈរដ្ឋមន្ត្រីក្លឺម៉ង់សូរលំទៅ ប្រទេសបារាំងបានប្រទះនឹងវិបត្តិគណៈរដ្ឋមន្ត្រីដល់ ទៅដប់ដងក្នុងរយៈវេលាតែ ៥ ឆ្នាំប៉ុណ្ណោះ (១៩០៩-១៩១៤) ។

* *បញ្ហាសង្គម* បានចោទខ្លាំងឡើងៗពីឆ្នាំ ១៩០៦ ដល់ ១៩១១ ។ សកម្ម ភាពរបស់សហជីពបដិវត្ត ដែលយកមធ្យោបាយកូដកម្មមកប្រើនោះ បានបង្ខំរដ្ឋាភិបាល ឲ្យស៊ើរៀបចំច្បាប់សង្គម ដើម្បីធ្វើឲ្យមានការធូរស្រាលខ្លះដល់វណ្ណៈកម្មករខ្លះទៅ ។

គេបានបង្កើតក្រសួងរដ្ឋមន្ត្រីការងារមួយ (១៩០៦) ហើយសំរេចឲ្យកម្មករសំរាកថ្ងៃ អាទិត្យ (១៩០៦) និងឲ្យមានសោធននិវត្តន៍ទៀតផង ។

នៅពេលជាមួយគ្នានោះ មានអ្នករដ្ឋការក្នុងអគ្គការខ្លះ ដូចជាគ្រូបង្រៀនជាដើម បាន ទំទាមទារសិទ្ធិបង្កើតសហជីពដែរ តែពុំទាន់បានសំរេចដូចបំណងនៅឡើយ ។

ដល់មកឆ្នាំ ១៩១៤ រពើតរពើងក្នុងសង្គមនិងទំនាស់នយោបាយក៏អន់ថយទៅវិញ ។ ម្យ៉ាងទៀត ស្ថានការណ៍សេដ្ឋកិច្ចក៏បានរីកចំរើនគ្រប់វិស័យជាលំដាប់ដែរ ។

## ៣. នយោបាយអាណានិគម

នយោបាយពង្រីកដែនដីអាណានិគមជាផលវិបាកនៃនយោបាយឧស្សាហូបនីយកម្មក្នុង ប្រទេសជាមហាអំណាចទាំងឡាយ ។

ដើម្បីរកវត្ថុធាតុដើម រកផ្សារ រកទីតាំងការពារនាវាចរ មហាអំណាចនានាគោង ស្វែងរកដែនដីអាណានិគមឲ្យបានច្រើន ។ ដូចនេះហើយ បានជានៅសតវត្សទី ១៩ ប្រទេសទន់ខ្សោយទាំងអស់ក្នុងលោកពុំអាចគេចផុតពីការជិះជាន់នៃមហាអំណាចឧស្សាហ កម្មឡើយ ។ នៅភាគទី ២ នៃសតវត្សទី ១៩ នេះ នយោបាយអាណានិគមបារាំង ត្រូវបានប្រព្រឹត្តទៅ ដោយពុះពារឧបសគ្គជាច្រើនគឺ ម្យ៉ាងមានការតិះដៀលជាខ្លាំង ពីសំណាក់ពលរដ្ឋបារាំងមួយភាគ ពិសេស បក្សសង្គមនិយម និងម្យ៉ាងទៀត ត្រូវប៉ះ ទង្គិចនឹងការលោភលន់នៃមហាអំណាចដទៃទៀត មានអង់គ្លេស អាឡឺម៉ង់ជាអាទិ ។ ក៏ប៉ុន្តែ ទោះជាមានការលំបាកដូចនេះក៏ដោយ អាស្រ័យដោយការមានះរបស់លោក

ស៊ិលភើរី ប្រទេសបារាំងនៅតែពង្រីកដែនដីអាណានិគមបានធំសំបើម ។

### ក. កំណើតនៃឥណ្ឌូចិនបារាំង

បារាំងដែលចូលមកកាន់កាប់ជ្រោយឥណ្ឌូចិនភាគខាងកើតនេះ គឺដើម្បីដើរកាត់ចូលទៅប្រទេសចិនភាគនិរតី ( វីនណាន Yunnan ) ដែលល្បីថាមានភោគទ្រព្យច្រើន ។

បន្ទាប់ពីបានត្រួតត្រាដែនដីកូសាំងស៊ីននិងកម្ពុជាមក (តាំងពីរាជ្យព្រះចៅណាប៉ូលេអុងទី ៣ មកម៉្លេះ) នយោបាយវាតទីលើជ្រោយឥណ្ឌូចិនហាក់ដូចជាត្រូវបានផ្អាកមួយគ្រាសិន ៗ ទើបតែដល់បានដំណឹងថា ទន្លេក្រហមដែលហូរកាត់ស្រុកយួនតុងកឹងនោះ អាចនាំនាវាចូលទៅដល់វីនណានបាន បារាំងក៏ចាប់ស្ទុះស្ទានាំទ័ពចូលទន្ទ្រានស្រុកយួនភាគខាងជើងនេះភ្លាម ៗ ក្រោយពីបានត្រូវអ្នកស្រុកយួន (ដោយមានកងកំលាំងចិនជួយផង) វាយច្រានឲ្យថយចេញជាច្រើនលើកមក បារាំងក៏យកជ័យជំនះបាន ហើយកាន់កាប់តុងកឹងព្រមទាំងអាណាមពេញលេញតាមសន្ធិសញ្ញាក្រុងធានជីង( Tien Tsin ) នៅឆ្នាំ ១៨៨៥ ។

ដល់ឆ្នាំ ១៨៨៧ បារាំងបានសំរេចប្រមូលប្រទេសទាំងអស់ ដែលគេវាយយកបាននៅឥណ្ឌូចិន ជាសហភាពមួយហៅថា សហភាពឥណ្ឌូចិន ។ រដ្ឋទាំងអស់ក្នុងសហភាពនេះគ្មានព្រំដែនសេដ្ឋកិច្ច និងហិរញ្ញវត្ថុទេ ។ ព្រំដែននយោបាយទៀតសោត ក៏សឹងតែឥតន័យទៀតផង ។ បន្ទាប់មក ប្រទេសលាវ ដែលលោក ប៉ាវី (Pavie) យកបានយ៉ាងស្រួលក្នុងឆ្នាំ ១៨៩៣ ក៏បានត្រូវបញ្ចូលទៅក្នុងសហភាពឥណ្ឌូចិននេះដែរ ។ សហភាពនេះមានអគ្គទេសាភិបាលជាតិបារាំងម្នាក់ ( Gouverneur Général ) ដែលស្នាក់នៅឯទីក្រុងព្រៃនគរ ជាអ្នកគ្រប់គ្រង ។

### ខ. កំណើតចក្រភពអាណានិគមបារាំងនៅទ្វីបអាព្រិច

នៅទ្វីបនេះ ដែនដីដែលចំណុះបារាំងពីដើមមក មាននៅតែតាមឆ្នេរសមុទ្រ ។ បារាំងបានយកទីនេះជាមូលដ្ឋាន ដើម្បីចេញដំណើរទៅវាយយកភូមិភាគដទៃទៀតនៃអាព្រិចខ្មៅ ។ នៅឆ្នាំ ១៨៨១ បារាំងវាយយកបានប្រទេសទុយនីស៊ី ដាក់ក្រោមអាណាព្យាបាលរបស់គេ ។ បន្ទាប់ពីយកបានស៊ូដង់ កូតឌីវ័រ និងដាហូមេមក គេកសាងបានអាព្រិចខាងលិចរបស់បារាំងមួយឡើង ( Afrique Occidentale Française ) ។

នៅឆ្នាំ ១៨៩០ បារាំងបានកាន់កាប់កោះម៉ាដាកាស្កា (Madagascar) ក្រោយដែល

បានព្រមព្រៀងប្រគល់ សង់ស៊ីបា (Zanzibar) ទៅឱ្យអង់គ្លេស ។ នៅលើកោះនេះ បារាំងត្រូវប្រើពេលអស់បួន-ដប់ឆ្នាំ ទើបអាចបង្ក្រាបចលនាតស៊ូនៃអ្នកស្រុកបាន ។

នៅដើមសតវត្សទី ២០ បារាំងយកបានប្រទេសម៉ារ៉ុកទៀត ។ គេប្រើល្បិចគាំទ្រព្រះចៅស៊ុលតង់ជ្រែករាជ្យមួយអង្គនាមមូឡៃ ហាភីត (Moulay Hafid) ដើម្បីបន្ទំប្រទេសនេះឱ្យប្រគល់រដ្ឋាភិបាលមកគេកាន់កាប់ ។

## សំណួរ

១. តើមានព្រឹត្តិការណ៍អ្វីកើតឡើងនៅប្រទេសបារាំង ក្រោយពេលដែលព្រះចៅណាប៉ូលេអុង ទី ៣ ត្រូវចាញ់ដៃទ័ពអាឡឺម៉ង់នៅក្រុងសេដង់ ?

២. កុំមូនក្រុងប៉ារី ជានិមិត្តរូបនៃទំនាស់អ្វី ?

៣. កលល្បិចរបស់លោក ម៉ាក់ម៉ាអុង ក្នុងការប៉ុនប៉ងស្ថាបនារបបរាជានិយមឡើងវិញនៅប្រទេសបារាំង ។

៤. ល័ក្ខខ័ណ្ឌធំៗដែលនាំអ្នកនិយមរបបសាធារណរដ្ឋឱ្យបែកគ្នាជាពីរក្រុម បន្ទាប់ពីលោកម៉ាក់ម៉ាអុង ត្រូវធ្លាក់ពីតំណែងទៅនោះ ។

៥. កិច្ចការកែទំរង់នៅសម័យសាធារណរដ្ឋកាលនិយម ។

៦. អធិប្បាយដោយសង្ខេបអំពីចលនាប៊ូឡង់សេនិយម ។

៧. បុព្វហេតុទូទៅដែលនាំឱ្យនយោបាយអាណានិគមលូតលាស់នៅសតវត្សទី ១៩ ។

៨. អធិប្បាយគ្រួសៗ អំពីកំណើតឥណ្ឌូចិនបារាំង ។

៩. តើសហភាពឥណ្ឌូចិនបារាំងមានផលវិបាកអ្វីខ្លះ សំរាប់ប្រទេសខ្មែរយើង ?

# ៦. សហរដ្ឋអាមេរិច
# ពីឆ្នាំ ១៨៦០ ដល់ ១៩១៤

ព្រឹត្តិការណ៍សំខាន់ៗដែលធ្វើឲ្យគេចាប់អារម្មណ៍បំផុត ពីសហរដ្ឋអាមេរិច នៅសម័យមុនសង្គ្រាមលោកលើកទីមួយ គឺការរីកចំរើនខាងទឹកដីនិងកំណើនប្រជាជន ។

រដ្ឋតូចៗចំនួន ១៣ ដែលឋិតនៅតាមបណ្ដោយឆ្នេរមហាសមុទ្រអាត្លង់ទិច ហើយដែលមានប្រជាជនមិនដល់ទៅពីរលាននាក់ផង បានក្លាយទៅជាសហព័ន្ធ (Fédération) មួយមានវិសាលភាពធំប្រហែលនឹងទ្វីបអឺរ៉ុបទាំងមូល និងមានប្រជាជនជិត ១០០ លាននាក់ តែក្នុងរយៈកាលប្រហែលមួយសតវត្សប៉ុណ្ណោះ ។

## ១. ការរីកចំរើនខាងទឹកដី

នៅឆ្នាំ ១៧៧៦ គឺឆ្នាំដែលជនជាតិអាមេរិកាំងបានបះបោរប្រឆាំងនឹងពួកអង់គ្លេស ដើម្បីទាមទារឯករាជ្យ សហរដ្ឋអាមេរិច (ស.រ.អ.) មានតែរដ្ឋតូចៗចំនួន ១៣ នៅតាមឆ្នេរមហាសមុទ្រអាត្លង់ទិច ។

នៅឆ្នាំ ១៧៨៣ *សន្ធិសញ្ញានៅក្រុងវែរសៃ* (Versailles) បានបង្ខំប្រទេសអង់គ្លេសឲ្យទទួលស្គាល់ឯករាជ្យ ស.រ.អ. ព្រមទាំងត្រូវប្រគល់ទឹកដីទៅឲ្យ ស.រ.អ. តាំងពីឆ្នេរមហាសមុទ្រអាត្លង់ទិច រហូតដល់ទន្លេមីស៊ីស៊ីពី (Mississipi) ។

តាំងពីបានឯករាជ្យមក ជនជាតិអាមេរិកាំងបានធ្វើឲ្យទឹកដីរបស់ខ្លួនកាន់តែរីកធំឡើងទៀត លាតសន្ធឹងរហូតទៅទល់នឹងមហាសមុទ្រប៉ាស៊ីភិច ។ ការពង្រីកទឹកដីនេះបានប្រព្រឹត្តទៅដោយទិញយកពីប្រទេសដទៃទៀតផង ដោយច្បាំងដណ្ដើមពីគេផង ជាលំដាប់លំដោយដូចតទៅ :

— នៅឆ្នាំ ១៨០៣ ស.រ.អ. បានទិញតំបន់ *លូវីស្យាន* (Louisiane) ពីបារាំង ។

— នៅឆ្នាំ ១៨១៩ ស.រ.អ. បានបង្ខំប្រទេសអេស្ប៉ាញ (Espagne) ឲ្យប្រគល់តំបន់ *ផ្លរីត* (Floride) ឲ្យខ្លួន ។

— នៅឆ្នាំ ១៨៤៥ ស.រ.អ. បានបង្ខំប្រទេសម៉ិចស៊ិច (Mexique) ឲ្យប្រគល់តំបន់ *តិចសាស់* (Texas) ឲ្យខ្លួន ។

— នៅឆ្នាំ ១៨៤៦ ស.រ.អ. បានបង្ខំប្រទេសអង់គ្លេសឲ្យប្រគល់តំបន់ *អូរេកុង* (Orégon) ឲ្យខ្លួន ហើយបានច្បាំងដណ្តើមយក *ម៉ិចស៊ិចថ្មី* (Nouveau Mexique) ពីប្រទេសម៉ិចស៊ិច ។

— នៅឆ្នាំ ១៨៤៨ ស.រ.អ. បានច្បាំងដណ្តើមយក *កាលីហ្វ័រនី* (Californie) ពីប្រទេសម៉ិចស៊ិច ។

— នៅឆ្នាំ ១៨៦៧ ស.រ.អ. បានទិញ *អាឡាស្កា* (Alaska) ពីរូស៊ី ។

## ២. កំណើនប្រជាជន

ជនជាតិដទៃជាច្រើន ពិសេសជនជាតិអឺរ៉ុបបាននាំគ្នាភៀសខ្លួនទៅតាំងនៅឯ ស.រ.អ. ជាហេតុញាំងប្រជាជននៃប្រទេសនេះឲ្យកើនចំនួនយ៉ាងច្រើនហើយយ៉ាងឆាប់រហ័ស ។ ឯបុព្វហេតុនៃការទៅតាំងនៅនោះមាន :

— វិបត្តិផ្សេងៗដែលកើតមាននៅទ្វីបអឺរ៉ុប ដូចជាចំបាំងនិងទុរ្ភិក្សនៅប្រទេសអៀរឡង់ (Irlande) នៅឆ្នាំ ១៨៤៥ ឬបដិវត្តន៍ឆ្នាំ ១៨៤៨ ជាដើម

— របកគំហើញមាសនៅកាលីហ្វ័រនី

— ការដែលគេដឹងថា ស.រ.អ. ជាប្រទេសថ្មី មានសល់ទឹកដីទំនេរច្រើន ហើយជាប្រទេសសំបូរទៅដោយភោគទ្រព្យធម្មជាតិផ្សេងៗ ដែលអាចញាំងអ្នកចំណូលថ្មីឲ្យមានជីវភាពខ្ពង់ខ្ពស់យ៉ាងឆាប់រហ័ស ។

ជនជាតិអឺរ៉ុបដែលបានទៅតាំងនៅ ស.រ.អ. ច្រើនជាងគេបំផុតគឺ ពួកអង់គ្លេស ពួកអៀរឡង់និងពួកអាល្លឺម៉ង់ ។ អ្នកដែលទៅតាំងនៅដំបូង ច្រើនតែជាអ្នកប្រមាញ់ អ្នកស្វែងរកស្បែកនិងរោមសត្វ កសិករ អ្នកចិញ្ចឹមសត្វ និងអ្នកស្វែងរកមាសប្រាក់ ។

ឧបសគ្គធំបំផុតដែលពួកអ្នកផ្សងព្រេងទាំងនោះបានជួបប្រទះ គឺព្រៃឈើ ។ ដោយ

មានតែកាំបិតនិងពូថៅ ពួកទាំងនោះបានកាប់គាស់ព្រៃឈើនៅកន្លែងណា ដែលបិតនៅជិតមាត់ទឹក ហើយសង់ខ្ទម បន្តជាភូមិស្រុកម្តងបន្តិចៗ ។ អ្នកទាំងនោះរស់ដោយសារផលដំណាំរបស់ខ្លួនមានពោតជាដើម និងដោយការបរបាញ់ ។

អ្នកខ្លះបានលក់ខ្ទមនិងចំការរបស់ខ្លួន ដើម្បីធ្វើដំណើរទៅទិសខាងលិចតទៅទៀត ។ អ្នកដែលមកដល់ក្រោយ បានកាប់ឆ្ការព្រៃ ពង្រីកចំការអស់នោះថែមទៀត ។ ផ្ទះថ្មីៗទៀតក៏ចេះតែកើនឡើងជាលំដាប់ ។

ឧបសគ្គមួយបែបទៀតរបស់គេ គឺចំបាំងដែលគេត្រូវធ្វើជាមួយនឹងជនជាតិអាមេរិកាំងស្បែកក្រហមដែលជាជនជាតិដើមផង និងម្ចាស់ស្រុកផង ហើយដែលប្រឆាំងនឹងអ្នកចំណូលថ្មី ដើម្បីរារាំងពួកនេះមិនឲ្យចូលទៅដណ្តើមយកទឹកដីរបស់គេ ។

ពួកអាមេរិកាំងស្បែកក្រហម ថ្វីត្បិតតែមានសេចក្តីក្លាហានយ៉ាងណាក៏ដោយ នៅមិនអាចទប់ទល់នឹងពួកអឺរ៉ុបផ្សងព្រេងបានឡើយ ដោយពួកនេះមានប្រៀបខាងសំភារៈសឹកៗម៉្លោះហើយ នៅកន្លែងខ្លះ ពួកអឺរ៉ុបផ្សងព្រេងបានកំទេចជនជាតិអាមេរិកាំងស្បែកក្រហមស្ទើរតែផុតពូជអស់ ។

លុះតំបន់ណាមួយមានមនុស្សច្រើនគួរសមហើយ គេក៏រៀបតំបន់នោះឲ្យបានទៅជារដ្ឋមួយឡើងហើយគេក៏បញ្ចូលរដ្ឋថ្មីនោះទៅក្នុងសហព័ន្ធរបស់គេ ។ ការបង្កើតរដ្ឋថ្មីទៀតចេះតែមានដំណើរទៅមុខជាលំដាប់ សំដៅទៅទិសខាងលិចនិងខាងត្បូង ។

ការពង្រីកទឹកដី និងដំណុះប្រជាជនសំដៅទៅទិសខាងត្បូងអាចប្រព្រឹត្តទៅបានយ៉ាងងាយដោយមានទន្លេមីស៊ីស៊ីពីជាផ្លូវគមនាគមន៍ ។ ដើម្បីសំរួលការពង្រីកទឹកដីទៅទិសខាងលិច គេបានស្ថាបនាផ្លូវរទេះភ្លើងនិងព្រែកជីក ។ នៅឆ្នាំ ១៨៤០ ប្រទេសបារាំងមានផ្លូវរទេះភ្លើងប្រវែងត្រឹមតែ ៩០០ គ.ម. ស.រ.អ. មានរហូតទៅ ៧០០០ គ.ម. ។ ស្ថិតិខាងក្រោមនេះជាភស្តុតាងបង្ហាញនូវកំណើនដ៏ឆាប់រហ័សនៃប្រជាជននៅ ស.រ.អ.:

នៅឆ្នាំ ១៧៧៦ ស.រ.អ. មានប្រជាជនចំនួន ១ ៦០០ ០០០ នាក់

នៅឆ្នាំ ១៨២៥ ស.រ.អ. មានប្រជាជនចំនួន ១០ ០០០ ០០០ នាក់

នៅឆ្នាំ ១៨៤០ ស.រ.អ. មានប្រជាជនចំនួន ១៧ ០០០ ០០០ នាក់

នៅឆ្នាំ ១៨៦០ ស.រ.អ. មានប្រជាជនចំនួន ៣១ ០០០ ០០០ នាក់

នៅឆ្នាំ ១៨៧០ ស.រ.អ. មានប្រជាជនចំនួន ៣៩ ០០០ ០០០ នាក់

នៅឆ្នាំ ១៨៩០ ស.រ.អ. មានប្រជាជនចំនួន ៦២ ០០០ ០០០ នាក់

នៅឆ្នាំ ១៩១៤ ស.រ.អ. មានប្រជាជនចំនួន ៩៥ ០០០ ០០០ នាក់

កំណើនប្រជាជនឆាប់រហ័សបែបនេះមិនមែនបណ្ដាលមកពីមានមនុស្សកើតច្រើនទេ គឺមកពីជនជាតិដទៃទៀតបាននាំគ្នាទៅតាំងនៅជាច្រើនឯស.រ.អ. ។ ហេតុនេះហើយបានជាស.រ.អ. បានស្គាល់បញ្ហាយ៉ាងស្មុគស្មាញខាងប្រជាជន ។

## ៣. បញ្ហាប្រជាជននៅ ស.រ.អ.

គឺបញ្ហាប្រកាន់ពណ៌សំបុរស្បែក ឬបញ្ហាប្រកាន់ជាតិសាសន៍ ។ ពួកអឺរ៉ុបបានប្រមូលទិញ ហើយបានដឹកនាំជនជាតិស្បែកខ្មៅជាច្រើនពីទ្វីបអាព្រិចទៅកាន់ ស.រ.អ. ដើម្បីយកទៅធ្វើជាទាសករ ជាហេតុនាំឲ្យមានជនជាតិអាព្រិចស្បែកខ្មៅច្រើននៅស.រ.អ. ។ ចំនួនជនជាតិអាព្រិចទាំងនោះមានច្រើនបំផុតនៅក្នុងរដ្ឋទាំងឡាយ ប៉ែកខាងត្បូងនៃស.រ.អ. ពីព្រោះនៅទីនោះ គេប្រើប្រាស់ពួកនេះជាទាសករ ក្នុងរបរកសិកម្ម ។

ទាសករស្បែកខ្មៅទាំងនេះមានកំរិតជីវភាពអន់ថយ រស់ដោយទុក្ខវេទនា ព្រមទាំងពុំបានស្គាល់សិទ្ធិ សេរីភាពដូចជាជនជាតិអាមេរិកាំងស្បែកសឡើយ ថ្វីបើមានច្បាប់លុបរបបទាសភាពក៏ដោយ ។ គេទាំងឡាយនោះត្រូវទទួលដោយឈឺចាប់នូវការរើសអើងខាងពណ៌សំបុរថែមទៀត ។ ជនជាតិទាំងនោះត្រូវមានទូរទេះភ្លើង សាលារៀន ភោជនីយដ្ឋាន វិហារ ឈាបនដ្ឋាន ។ល។ ដោយឡែកពីជនជាតិស្បែកស ។ ឯអាពាហ៍ពិពាហ៍រវាងជនស្បែកសនិងស្បែកខ្មៅក៏ត្រូវបានហាមឃាត់ដែរ ។

ការតវ៉ា ឬចលាចលបន្តិចបន្តួចជាបុព្វហេតុបណ្ដាលឲ្យពួកស្បែកសរករឿងសំលាប់ពួកស្បែកខ្មៅតាមអំពើចិត្ត : សំលាប់ដោយគ្រាប់កាំភ្លើង ដោយព្យួរក ឬដោយដុតទាំងរស់ ។ រួមសេចក្ដីមក គេទុកពួកស្បែកខ្មៅឲ្យនៅក្រៅសង្គមរបស់គេ ។

បញ្ហាពណ៌សំបុរស្បែកនេះក៏ត្រូវបានចោទចំពោះជាតិដទៃទៀតដែរ មានជនជាតិចិននិងជប៉ុនជាដើម ដែលបានទៅតាំងនៅជាច្រើនដែរនៅ ស.រ.អ. គេក៏បានតាក់តែងច្បាប់ដើម្បីរារាំងកុំឲ្យជនជាតិដទៃទៀតទៅតាំងនៅឯ ស.រ.អ. បានរហូតដល់ទៅជនជាតិស្បែកសដូចគ្នា ក៏គេហាមឃាត់ដែរ ដូចជាជនជាតិជ្វីប (Juif) ជាដើម ។

បញ្ហាប្រកាន់ពណ៌សំបុរស្បែកនេះបណ្ដាលឲ្យមានសង្គ្រាមរវាងគ្នាឯងនៅ ស. រ. អ. ហើយបញ្ហានេះនៅតែមានចោទឡើងរហូតមកដល់បច្ចុប្បន្នកាលនេះ ។

## ៤. ចំបាំងបំបែកស្រុក (Guerre de Sécession)

ជនជាតិអាមេរិកាំងដែលឋិតនៅប៉ែកខាងត្បូងនៃ ស.រ.អ. ច្រើនតែជាពួកកសិករ (ដាំកប្បាសជាដើម) ឬជាពួកអ្នកចិញ្ចឹមសត្វ ។ ពួកអ្នកទាំងនោះត្រូវការទាសករស្បែកខ្មៅជាជំនួយក្នុងមុខរបររបស់គេ ។ ដូចនេះហើយ បានជាពួកអ្នកទាំងនោះប្រឆាំងនឹងច្បាប់លុបបំបាត់ទាសភាព ដែលកំហែងគំរាមផលប្រយោជន៍របស់គេ ។

ផ្ទុយទៅវិញ ជនជាតិអាមេរិកាំងដែលតាំងនៅប៉ែកខាងជើងនៃ ស.រ.អ. ច្រើនតែជាពួកឧស្សាហករ ។ ពួកអ្នកទាំងនេះមានបំណងចង់ឲ្យលុបបំបាត់ទាសភាពចោលពីដែនដីនៃ ស.រ.អ. ទាំងមូល ដើម្បីធ្វើឲ្យជនជាតិអាមេរិកាំងគ្រប់ពណ៌សំបុរមានសិទ្ធិសេរីភាពស្មើៗគ្នាទាំងអស់ ។

ពួកអាមេរិកាំងដែលមានបំណងចង់លុបបំបាត់ទាសភាព បានបង្កើតគណបក្សនយោបាយមួយហៅថា «*គណបក្សសាធារណរដ្ឋ*» (Parti Républicain) ដែលឋិតក្រោមការដឹកនាំរបស់លោក *អាប្រាហាម លិងកូល* (Abraham Lincoln) ។ នៅឆ្នាំ ១៨៦០ គណបក្សនេះបានឈ្នះឆ្នោត ហើយលោកអាប្រាហាម លិងកូល ក៏ត្រូវបានគេជ្រើសរើសឲ្យធ្វើប្រធានាធិបតីត្រួតត្រាលើ ស. រ. អ. ទាំងមូល ។



*លោក អាប្រាហាម លិងកូល (១៨០៩-១៨៦៥)*

ដោយដឹងថា គេមុខជានឹងលុបបំបាត់ទាសភាពចោល រដ្ឋប៉ែកខាងត្បូងចំនួន១១ បានសុំដកខ្លួនចេញពីសហព័ន្ធ ដើម្បីនាំគ្នាទៅបង្កើតសហព័ន្ធមួយថ្មីទៀត ។ ក៏ប៉ុន្តែ លោកប្រធានាធិបតីមិនព្រមជាដាច់ខាត ហើយមិនបណ្តោយឲ្យមានការបាក់បែកគ្នាយ៉ាងនេះឡើយ ។ សង្គ្រាមរវាងពួកខាងជើងនិងពួកខាងត្បូងក៏បានផ្ទុះឡើង ។ សង្គ្រាមនេះបានប្រព្រឹត្តទៅពីខែមេសា ឆ្នាំ ១៨៦១ ដល់ខែឧសភាឆ្នាំ ១៨៦៥ យ៉ាងសាហាវឃោរឃៅ បណ្តាលឲ្យខូចសំភារៈ និងបាត់បង់ជីវិតមនុស្សអស់ជាច្រើន ។

ពួកខាងជើងមានមនុស្សច្រើន មានគ្រឿងអាវុធស្ដុកស្ដម្ភជាងពួកខាងត្បូង ។ ឯពួកខាងត្បូងសុទ្ធតែជាអ្នកជំនាញ ថ្នឹកក្នុងរឿងចំបាំង ។ នៅទីបំផុត ពួកខាងជើងបានទទួលជ័យជំនះ ។ ក៏ប៉ុន្តែ ក្នុងអំឡុងប៉ុន្មានថ្ងៃក្រោយពីការបញ្ចប់សង្គ្រាមមក ពួកខាងត្បូងម្នាក់បានលបធ្វើឃាតលោកប្រធានាធិបតីលិងកូល ។

ជ័យជំនះរបស់ពួកខាងជើង ក្នុងសង្គ្រាមបំបែកស្រុកនេះ បណ្តាលឲ្យមានផលវិបាកពីរយ៉ាងសំខាន់ចំពោះ ស.រ.អ. គឺ

— ស.រ.អ. ឋិតនៅរួបរួមគ្នាជាឯកភាពក្នុងសហព័ន្ធតែមួយដដែល

— ច្បាប់លុបបំបាត់ទាសភាពត្រូវយកមកអនុវត្តក្នុងដែនដី ស.រ.អ. ទាំងមូល ជាហេតុនាំឲ្យជនជាតិអាមេរិកាំងគ្រប់ពណ៌សំបុរទាំងអស់ ជាពិសេសពួកស្បែកខ្មៅ ត្រូវមានសិទ្ធិសេរីភាពស្មើៗគ្នា ។

## ៥. សភាពនយោបាយនៅ ស.រ.អ.

រដ្ឋធម្មនុញ្ញដែល ស.រ.អ. បានតាក់តែងតាំងពីឆ្នាំ ១៧៨៧ បានត្រូវយកមកប្រើប្រាស់រហូតមកដល់សម័យបច្ចុប្បន្ននេះ ដោយគ្រាន់តែមានការកែប្រែបន្តិចបន្តួច ដើម្បីសំរបសំរួលទៅតាមកាលៈទេសៈប៉ុណ្ណោះ ។ រដ្ឋធម្មនុញ្ញនេះបានរៀបចំរបបគ្រប់គ្រង ស.រ.អ. ឲ្យមានសភាពដូចតទៅ :

ក. នយោបាយក្នុងប្រទេស

រដ្ឋនីមួយៗ (សព្វថ្ងៃមានចំនួន ៥០) មានរបៀបគ្រប់គ្រងផ្ទៃក្នុង និងទំនៀមទំលាប់ពិសេសសំរាប់ខ្លួន ដូចជាច្បាប់ខាងតុលាការជាដើម ។ បញ្ហាណាដែលទាក់ទងទៅនឹង

សហព័ន្ធទាំងមូល ដូចជាចំបាំង កិច្ចការទូត ពាណិជ្ជកម្មក្រៅប្រទេស ឬរូបិយវត្ថុជាដើមត្រូវឋិតនៅលើការចាត់ចែងរបស់រដ្ឋាភិបាលសហព័ន្ធ ។

ប្រធានាធិបតីដែលជាអ្នកកាន់អំណាចនីតិប្រតិបត្តិ ត្រូវជ្រើសរើសដោយវិធីបោះឆ្នោតក្នុងចំណោមបេក្ខជនពីររូប ដែលជាតំណាងនៃគណបក្សនយោបាយទាំងពីរ គឺគណបក្សសាធារណរដ្ឋ និងគណបក្សប្រជាធិបតេយ្យ ។ អាណត្តិប្រធានាធិបតីមានរយៈកាល ៤ ឆ្នាំ ។ ប្រធានាធិបតីអាចតែងតាំង «លេខាធិការ» ជាច្រើនរូបធ្វើជាសហការីរបស់ខ្លួន (នៅ ស.រ.អ. «លេខាធិការ» នេះមានមុខងារជារដ្ឋមន្ត្រី) ។

អំណាចនីតិបញ្ញត្តិជាភារៈរបស់សមាជអាមេរិកាំង ដែលមានសភាទាំងពីរជួយធ្វើការអមជង គឺរដ្ឋសភា និងព្រឹទ្ធសភា (Sénat) ។ ក្នុងរដ្ឋសភា រដ្ឋនីមួយៗមានតំណាងរាស្ត្រតិចឬច្រើនតាមចំនួនប្រជាជនក្នុងរដ្ឋនោះ ។ ចំណែកនៅក្នុងព្រឹទ្ធសភាវិញ រដ្ឋនីមួយៗអាចមានតំណាងតែ ២ រូបទេ ។

ក្រៅពីអង្គការទាំងនេះ នៅមានអង្គការសំខាន់មួយទៀតឈ្មោះ *តុលាការជាន់ខ្ពស់* (Cour Suprême) ដែលមានភារកិច្ចរកយុត្តិធម៌ វិនិច្ឆ័យវិវាទរវាងរដ្ឋនិងរដ្ឋ រវាងរដ្ឋនិងសហព័ន្ធ ឬវិនិច្ឆ័យគ្រប់បញ្ហាទាំងឡាយដែលហួសពីសមត្ថកិច្ចរបស់រដ្ឋ ឬរបស់សហព័ន្ធ ។

គួរកត់សំគាល់ថា ប្រធានាធិបតីនៅ ស.រ.អ. កាន់មុខតំណែងដូចជានាយករដ្ឋមន្ត្រីនៅប្រទេសដទៃទៀត ហើយមានអំណាចទូលំទូលាយណាស់ ពីព្រោះប្រធានាធិបតី ស.រ.អ. បានទទួលអំណាចផ្ទាល់ពីប្រជារាស្ត្រតែម្តង ដោយវិធីបោះឆ្នោត ដែលធ្លាប់បានប្រព្រឹត្តទៅដូចតទៅនេះ គឺបួនឆ្នាំម្តង គណបក្សនយោបាយទាំងពីរបានប្រជុំនយោបាយក្នុងគណបក្ស ដើម្បីជ្រើសរើសរកបេក្ខជនណាមួយជាតំណាងគណបក្សរបស់ខ្លួន ។ ក្នុងរវាងបីខែ បេក្ខជនទាំងពីររូប ដែលត្រូវបានជ្រើសរើសជាតំណាង ត្រូវធ្វើការឃោសនាយ៉ាងសកម្មនៅគ្រប់រដ្ឋ ។ លុះគ្រប់កំណត់បីខែហើយ បេក្ខជនទាំងពីររូបនេះត្រូវប្រគល់ខ្លួនទៅឲ្យតំណាងប្រជារាស្ត្រ(១) បោះឆ្នោតជ្រើសរើសយកបេក្ខជនណាម្នាក់ឲ្យធ្វើជាប្រធានាធិបតីក្នុងរយៈកាលបួនឆ្នាំ ។

---

*(១) ក្នុងរដ្ឋនីមួយៗ ប្រជារាស្ត្របោះឆ្នោតជាសកលរើសតំណាងសំរាប់ទៅបោះឆ្នោតរើសប្រធានាធិបតីជំនួសគេ ។*

## ខ. នយោបាយក្រៅប្រទេស

នៅឆ្នាំ ១៩១៤ ស.រ.អ. បានក្លាយទៅជាមហាអំណាចមួយសំខាន់ជាងគេបំផុតក្នុងលោក ជាពិសេសខាងផ្នែកសេដ្ឋកិច្ច ។ ស.រ.អ. បានឡើងឋានៈលេខមួយគ្រប់វិស័យទាំងអស់ មានជាអាទិ៍ផលិតផលកសិកម្មនិងឧស្សាហកម្ម ។ ស្ថានភាពដ៏ប្រសើរនេះបានធ្វើឲ្យ ស.រ.អ. ចេញមុខយ៉ាងសង្ហាលើឆាកអន្តរជាតិ ។

លោកប្រធានាធិបតីម៉ុងរេ (Monroë) បានប្រកាសលទ្ធិមួយថា *«ទ្វីបអាមេរិចសំរាប់តែពួកអាមេរិកាំង»* បានសេចក្ដីថា ជនជាតិដទៃទៀតមិនត្រូវចូលទៅជ្រៀតជ្រែកក្នុងរឿងដែលមានកើតឡើងនៅទ្វីបអាមេរិចឡើយ ។

តាំងពីពេលនោះមក ឲ្យតែមានវិវាទរវាងប្រទេសណាមួយនៅទ្វីបអាមេរិច ជាមួយនឹងប្រទេសដទៃទៀត ស.រ.អ. តែងតែបង្ខំគូវិវាទនោះឲ្យទទួល ស.រ.អ. ធ្វើជាអាជ្ញាកណ្ដាលជានិច្ច ។ ម្យ៉ាងទៀត ស.រ.អ. បានធ្វើអន្តរាគមន៍ជាញឹកញយក្នុងវិបត្តិនានាដែលបានកើតឡើងនៅក្នុងលោក ។

នៅឆ្នាំ ១៨៩៨ ស.រ.អ. បានច្បាំងនឹងប្រទេសអេស្ប៉ាញ (Espagne) ដើម្បីដណ្ដើមយកកោះគុយបា (Cuba) កោះពរតូរីកូ (Porto Rico) និងភីលីពីន (Philippines) ។



*(ផែនទីសហរដ្ឋអាមេរិចក្នុងពេលពង្រីកទឹកដី)*

នៅឆ្នាំ ១៩១៤ ស.រ.អ. បានពង្រីកអំណាចនយោបាយ និងសេដ្ឋកិច្ចទៅលើប្រទេស ម៉ិចស៊ិច និងអាមេរិចកណ្ដាល ហើយបានមកប្រណាំងប្រជែងជាមួយនឹងជប៉ុននៅចុងបូព៌ាប្រទេស ។

នៅឆ្នាំ ១៩១៧ ស.រ.អ. បានធ្វើអន្តរាគមន៍ក្នុងសង្គ្រាមលោកលើកទីមួយ ។

សហរដ្ឋអាមេរិចដែលពីដើមសុទ្ធតែជារដ្ឋតូចៗ ឋិតនៅក្រោមអំណាចបារាំង ហើយបន្ទាប់មកក្រោមអំណាចអង់គ្លេស បានរើខ្លួនឲ្យបានឯករាជ្យនៅឆ្នាំ ១៧៨៣ ហើយបានក្លាយទៅជាមហាអំណាចមួយសំខាន់ជាងគេបំផុតក្នុងលោក នៅឆ្នាំ ១៩១៤ ។

## សំណួរ

១. គូរផែនទីបង្ហាញការពង្រីកទឹកដីនៅ ស.រ.អ. ។

២.ពន្យល់អំពីកំណើនប្រជាជននៅ ស.រ.អ. ។

៣. រៀបរាប់អំពីបុព្វហេតុ និងផលវិបាកនៃសង្គ្រាមរវាងគ្នាឯងនៅ ស.រ.អ. ។

៤. បង្ហាញលក្ខណៈនៃលទ្ធិប្រជាធិបតេយ្យនៅ ស.រ.អ. ។

# ៧. ចក្រភពរូស៊ី
# ពីឆ្នាំ១៨៥៥ ដល់ ១៩១៧

ចាប់ពីសតវត្សទី ១៨ មក ដោយឥទ្ធិពលនៃវប្បធម៌អឺរ៉ុបខាងលិចដែលបានជ្រួតជ្រាបចូលទៅក្នុងចក្រភពរូស៊ី ព្រះរាជានៃចក្រភពនេះជាច្រើនអង្គ មានព្រះចៅ *ព្យែរឡឺក្រង់* (Pierre le Grand) និងព្រះមហារាជិនី *កាតឺរីនទី ២* (Catherine II) ជាដើមបានរៀបចំប្រទេសជាតិ និងសង្គមជាតិឱ្យមានការលូតលាស់ខ្លះប្លែកពីមុន ៗ ដំណើរនៃការស្ថាបនាប្រទេសជាតិនេះ កាន់តែមានទំហំធំឡើងទៀត នៅពាក់កណ្ដាលសតវត្សទី ១៩ គឺក្នុងរាជ្យព្រះចៅ*អាឡិចសង់ទី ២* (Alexandre II) ដែលព្រះអង្គទ្រង់បានប្រកាសអនុវត្តកម្មវិធីកែទំរង់របៀបគ្រប់គ្រង សេដ្ឋកិច្ចនិងសង្គម ។

ជាមួយគ្នានឹងកំណែទំរង់នេះ គេសង្កេតឃើញថា គំនិតនិងចលនាបដិវត្តន៍ក៏ចេះតែដុះដាលជាលំដាប់ដែរ ។ បញ្ញវន្តរូស៊ីដែលកាន់តែមានចំនួនច្រើនឡើង ក៏ដុះគំនិតប៉ង់រំលំរបបគ្រប់គ្រងចាស់ចោល ។ រីឯជនជាតិនានា មានប៉ូឡូញជាដើមដែលត្រូវចក្រភពរូស៊ីជិះជាន់និងរំលោភយកទឹកដីនោះ ក៏បានខិតខំដណ្ដើមយកឯករាជ្យខ្លួនមកវិញ ។

ប្រតិកម្មនៃវណ្ណៈអភិជនអ្នកកាន់អំណាចប្រឆាំងនឹងគំនិតថ្មី ព្រមទាំងវិបត្តិសេដ្ឋកិច្ចនិងសង្គម បានជំរុលចលនាបដិវត្តន៍ឱ្យផុសជាកំលាំងទាមទារសិទ្ធិសេរីភាព និងលទ្ធិប្រជាធិបតេយ្យ ។ បាតុកម្មសំដែងកំហឹងនៃមហាជនក៏ចេះតែកើតមានឡើងជាលំដាប់ ពិសេសនៅឆ្នាំ ១៩០៥ ដែលគេអាចចាត់ទុកបានថាជាការសមកំលាំងនៃប្រជារាស្ត្រ សំរាប់វាយរំលំផ្ដាច់ព្រ័ត្រនូវរបបរាជានិយមផ្ដាច់ការរូស៊ី ក្នុងខែតុលា ឆ្នាំ ១៩១៧ ។

## ១. ប្រទេសរូស៊ីមុនរជ្ជកាលព្រះចៅអាឡិចសង់ ទី ២

### ក. ចក្រភពរូស៊ី

ដល់មករាជ្យព្រះចៅ*អាឡិចសង់ទី២* ទំហំនៃចក្រភពរូស៊ីស៊ីងតែប្រហាក់ប្រហែលផ្ទៃដី


ការវាតដែនដីនៃចក្រភពរុស្ស៊ី
នៅសតវត្សទី១៧
នៅសតវត្សទី១៨
នៅសតវត្សទី១៩
មូស្គូ
រុស្ស៊ីធំ
សមុទ្រខ្មៅ

ផ្នែករុស្ស៊ី អឺរ៉ុប